# អភិធម្មបិដក



១០៨

# ABHIDHAMMA PITAKA

# ព្រះ

# ត្រៃបិដកបាលី

# និង

# សេចក្ដីប្រែជាភាសាខ្មែរ

# អភិធម្មបិដក

# បដ្ឋាន បណ្ណរសមភាគ

# ១០៨



ផ្សព្វផ្សាយដោយសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា

*ព. ស. ២៥៥៣*

# ABHIDHAMMAPIṬAKA

## PAṬṬHĀNA

## PAṆṆARASAMABHĀGA

# 108

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមឌ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammayutt Sangkat Chatumuk Khan Daun Penh P.Penh

ទំព័រទទេ

# សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

*ឧទាហរណ៍*

-ពាក្យខ្មែរៈ **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សង្ខិតច្បាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# អភិធម្មបិដក

# បដ្ឋាន បណ្ណាសមភាគ

១០៨

ព. ស. ២៥១២

# អភិធម្មបិដកេ

## បដ្ឋានស្ស បណ្ណរសមោ ភាគោ

## បច្ចនីយប្បដ្ឋានំ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បច្ចនីយត្តិកប្បដ្ឋានំ

### នកុសលត្តិកំ

[១] នកុសលំ ធម្មំ បដិច្ច នកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អកុសលំ អព្យាកតំ ឯកំ ខន្ធំ បដិច្ច អកុសលោ អព្យាកតោ តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច ទ្វេ ខន្ធា ចិត្ត-សមុដ្ឋានញ្ច រូបំ ។ នកុសលំ ធម្មំ បដិច្ច ន អកុ-សលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ធម្មំ បដិច្ច ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុ-ប្បច្ចយា ន កុសលំ ធម្មំ បដិច្ច ន កុសលោ ច ន អព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន កុសលំ ធម្មំ បដិច្ច ន កុសលោ ច ន អកុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

# អភិធម្មបិដក

# បដ្ឋាន បណ្ណរសមភាគ

# បច្ចនីយប្បដ្ឋាន

---

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## បច្ចនីយត្តិកប្បដ្ឋាន

## នកុសលត្តិកៈ

[១] *ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ជាអកុសល ជាអព្យាកតៈក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវខន្ធ ១ ជាអកុសល ជាអព្យាកតៈ ខន្ធ ២ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវខន្ធ ២ ។ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។*

[២] ន អកុសលំ ធម្មំ បដិច្ច ន អកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អកុសលំ ធម្មំ បដិច្ច ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អកុសលំ ធម្មំ បដិច្ច ន អព្យាកតោ ធម្មោ ឧប្ប-ជ្ជតិ ហេតុប្បច្ចយា ន អកុសលំ ធម្មំ បដិច្ច ន អកុសលោ ច ន អព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន អកុសលំ ធម្មំ បដិច្ច ន កុស-លោ ច ន អកុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្ប-ច្ចយា បញ្ច ។

[៣] ន អព្យាកតំ ធម្មំ បដិច្ច ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អព្យាកតំ ធម្មំ បដិច្ច ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អព្យាកតំ ធម្មំ បដិច្ច ន អកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អព្យាកតំ ធម្មំ បដិច្ច ន កុសលោ ច ន អព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន អព្យាកតំ ធម្មំ បដិច្ច ន អកុ-សលោ ច ន អព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ

[២] ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុប្ប-ច្ច័យ ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុ-ប្បច្ច័យ មានវារៈ ៥ ។

[៣] ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុ-សល អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះ ហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ ទើបកើតឡើង

៣

បច្ចនីយត្តិកប្បដ្ឋានំ

ហេតុប្បច្ចយា ន អព្យាកតំ ធម្មំ បដិច្ច ន កុស-លោ ច ន អកុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុ-ប្បច្ចយា ឆ ។

[៤] ន កុសលញ្ច ន អព្យាកតញ្ច ធម្មំ បដិច្ច ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុ-សលញ្ច ន អព្យាកតញ្ច ធម្មំ បដិច្ច ន អកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលញ្ច ន អ-ព្យាកតញ្ច ធម្មំ បដិច្ច ន អព្យាកតោ ធម្មោ ឧប្ប-ជ្ជតិ ហេតុប្បច្ចយា ន កុសលញ្ច ន អព្យាកតញ្ច ធម្មំ បដិច្ច ន កុសលោ ច ន អព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន កុសលញ្ច ន អព្យាក-តញ្ច ធម្មំ បដិច្ច ន កុសលោ ច ន អកុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

[៥] ន អកុសលញ្ច ន អព្យាកតញ្ច ធម្មំ បដិច្ច ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ច-យា ន អកុសលញ្ច ន អព្យាកតញ្ច ធម្មំ បដិច្ច ន អកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អកុសលញ្ច ន អព្យាកតញ្ច ធម្មំ បដិច្ច ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[៤] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[៥] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាអកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាអកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាអកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ន អកុសលញ្ច ន អព្យាកតញ្ច ធម្មំ បដិច្ច ន អកុសលោ ច ន អព្យាកតោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន អកុសលញ្ច ន អព្យាកតញ្ច ធម្មំ បដិច្ច ន កុសលោ ច ន អកុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

[៦] ន កុសលញ្ច ន អកុសលញ្ច ធម្មំ បដិច្ច ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលញ្ច ន អកុសលញ្ច ធម្មំ បដិច្ច ន អកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលញ្ច ន អកុសលញ្ច ធម្មំ បដិច្ច ន កុសលោ ច ន អកុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។

[៧] ន អកុសលំ ធម្មំ បដិច្ច ន អកុសលោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា ។

[៨] ហេតុយា ឯកូនតឹស អារម្មណេ ចតុវីស អវិគតេ ឯកូនតឹស ។

សហជាតវារម្បិ បច្ចយវារម្បិ និស្សយវារម្បិ សំសដ្ឋវារម្បិ សម្បយុត្តវារម្បិ បដិច្ចវារសទិសំ ។

[៩] ន កុសលោ ធម្មោ ន កុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

ធម៌ មិនមែនជាអកុសលក្តី មិនមែនជាអព្យាកតៈក្តី អាស្រ័យ នូវធម៌ មិនមែនជាអកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ មិនមែនជាអកុសលផង មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[៦] ធម៌ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[៧] ធម៌ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាអកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[៨] ក្នុងហេតុប្បច្ច័យ មានវារៈ ២៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៩ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៩] ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយហេតុប្បច្ច័យ ។

៤

បច្ចនីយត្តិកប្បដ្ឋានំ

[១០] ន កុសលោ ធម្មោ ន កុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ន កុសលោ ធម្មោ ន អកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ន កុសលោ ធម្មោ ន អព្យាកតស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ន កុសលោ ធម្មោ ន កុសលស្ស ច ន អព្យាកតស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ន កុសលោ ធម្មោ ន អកុសលស្ស ច ន អព្យាកតស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ន កុសលោ ធម្មោ ន កុសលស្ស ច ន អកុសលស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ៩ ។ ន អកុសលោ ធម្មោ ន អកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ៩ ។ ន អព្យាកតោ ធម្មោ ន អព្យាកតស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ៩ ។ ន កុសលោ ច ន អព្យាកតោ ច ធម្មា ន កុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ៩ ។ ន អកុសលោ ច ន អព្យាកតោ ច ធម្មា ន កុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ៩ ។

## បច្ចនីយត្តិកបដ្ឋាន

[១០] ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអកុសល ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសលផង មិនមែនជាអព្យាកតៈផង ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអកុសលផង មិនមែនជាអព្យាកតៈផង ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។ ធម៌ មិនមែនជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។ ធម៌ មិនមែនជាអព្យាកតៈ ជាបច្ច័យ នៃធម៌ មិនមែនជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអព្យាកតៈក្តី ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។ ធម៌ មិនមែនជាអកុសលក្តី មិនមែនជាអព្យាកតៈក្តី ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។

ន កុសលោ ច ន អកុសលោ ច ធម្មា ន កុស-លស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឆ ។

[១១] ន កុសលោ ធម្មោ ន កុសលស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អនន្តរប្បច្ចយេន បច្ចយោ សមនន្តរ . . . សហជាត . . . អញ្ញមញ្ញ . . . និស្សយ . . . ឧបនិស្សយ . . . ។

[១២] . . . បុរេជាតប្បច្ចយេន បច្ចយោ ន កុស-លោ ធម្មោ ន អកុសលស្ស ធម្មស្ស បុរេជាតប្ប-ច្ចយេន បច្ចយោ ន កុសលោ ធម្មោ ន កុសលស្ស ច ន អកុសលស្ស ច ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ ។ ន អកុសលោ ធម្មោ ន អកុសលស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ ន អកុសលោ ធម្មោ ន កុសលស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ ន អកុសលោ ធម្មោ ន កុសលស្ស ច ន អកុសលស្ស ច ធម្មស្ស បុរេជាតប្បច្ចយេន បច្ច-យោ ។ ន កុសលោ ច ន អកុសលោ ច ធម្មា ន កុសលស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ ន កុសលោ ច ន អកុសលោ ច ធម្មា ន អកុ-សលស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ

ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៦ ។

[១១] ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយអធិបតិប្បច្ច័យ ជាបច្ច័យ ដោយអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ . . . សហជាតប្បច្ច័យ . . . អញ្ញមញ្ញប្បច្ច័យ . . . និស្សយប្បច្ច័យ . . . ឧបនិស្សយប្បច្ច័យ . . . ។

[១២] . . . ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអកុសល ដោយបុរេជាតប្បច្ច័យ ធម៌ មិនមែនជាកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ដោយបុរេជាតប្បច្ច័យ ។ ធម៌ មិនមែនជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាអកុសល ដោយបុរេជាតប្បច្ច័យ ធម៌ មិនមែនជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយបុរេជាតប្បច្ច័យ ធម៌ មិនមែនជាអកុសល ជាបច្ច័យ នៃធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ដោយបុរេជាតប្បច្ច័យ ។ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី ជាបច្ច័យ នៃធម៌ មិនមែនជាកុសល ដោយបុរេជាតប្បច្ច័យ ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី ជាបច្ច័យ នៃធម៌ មិនមែនជាអកុសល ដោយបុរេជាតប្បច្ច័យ

ន កុសលោ ច ន អកុសលោ ច ធម្មោ ន កុសលស្ស ច ន អកុសលស្ស ច ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ ។

[១៣] ហេតុយា ឯកូនត្តឹស អារម្មណេ ឆត្តឹស អធិបតិយា បញ្ចត្តឹស អនន្តរេ ចតុត្តឹស សមនន្តរេ ចតុត្តឹស សហជាតេ ឯកូនត្តឹស អញ្ញមញ្ញេ ចតុព្វីស និស្សយេ ចតុត្តឹស ឧបនិស្សយេ ឆត្តឹស បុរេជាតេ អដ្ឋារស បច្ឆាជាតេ អដ្ឋារស អាសេវនេ ចតុព្វីស កម្មេ ឯកូនត្តឹស វិបាកេ នវ អាហារេ ឯកូនត្តឹស អវិគតេ ចតុត្តឹស ។

យថា កុសលត្តិកេ បញ្ហាវារស្ស អនុលោមម្បិ បច្ចនីយម្បិ អនុលោមប្បច្ចនីយម្បិ បច្ចនីយានុលោមម្បិ គណិតំ ឯវំ គណេតព្វំ ។

# នវេទនាត្តិកំ

[១៤] ន សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច ន សុខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច ន ទុក្ខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ

ធម៌ មិនមែនជាកុសលក្តី មិនមែនជាអកុសលក្តី ជាបច្ច័យ នៃធម៌ មិនមែនជាកុសលផង មិនមែនជាអកុសលផង ដោយបុរេជាតប្បច្ច័យ ។

[១៣] ក្នុងហេតុប្បច្ច័យ មានវារៈ ២៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ២៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២៤ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣៤ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១៨ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ១៨ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២៤ ក្នុងកម្មប្បច្ច័យ មានវារៈ ២៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ២៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣៤ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈ ដែលយើងរាប់ហើយ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិត គប្បីរាប់យ៉ាងនោះចុះ ។

# នវេទនាត្តិកៈ

[១៤] ធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនា អាស្រ័យនូវធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនសម្បយុត្តដោយទុក្ខវេទនា អាស្រ័យនូវធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនា ទើបកើតឡើង

ហេតុប្បច្ចយា ន សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច ន អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច ន សុខាយ វេទនាយ សម្បយុត្តោ ច ន អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច ន ទុក្ខាយ វេទនាយ សម្បយុត្តោ ច ន អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច ន សុខាយ វេទនាយ សម្បយុត្តោ ច ន ទុក្ខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច ន សុខាយ វេទនាយ សម្បយុត្តោ ច ន ទុក្ខាយ វេទនាយ សម្បយុត្តោ ច ន អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន ទុក្ខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច ន ទុក្ខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សត្ត ។

ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនសម្បយុត្តដោយអទុក្ខមសុខវេទនា អាស្រ័យ នូវធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទ-នាក្តី មិនមែនសម្បយុត្តដោយអទុក្ខមសុខវេទនាក្តី អាស្រ័យ នូវធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុ-ប្បច្ច័យ ធម៌ ដែលមិនមែនសម្បយុត្តដោយទុក្ខវេទនាក្តី មិនមែនសម្បយុត្តដោយអទុក្ខមសុខវេទនាក្តី អាស្រ័យ នូវធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនាក្តី មិនមែនសម្បយុត្តដោយទុក្ខ-វេទនាក្តី អាស្រ័យ នូវធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនាក្តី មិនមែនសម្បយុត្តដោយទុក្ខវេទនាក្តី មិនមែនសម្បយុត្តដោយអទុក្ខមសុខវេទនាក្តី អាស្រ័យ នូវធម៌ ដែលមិនមែនសម្បយុត្តដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ ដែលមិនមែនសម្បយុត្តដោយទុក្ខវេទនា អាស្រ័យ នូវធម៌ ដែលមិនមែនសម្ប-យុត្តដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។

ន អនុក្ខមសុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច ន អនុក្ខមសុខាយ វេទនាយ សម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សត្ត ។

# នវិបាកត្តិកំ

[១៥] ន វិបាកំ ធម្មំ បដិច្ច ន វិបាកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ ន វិបាកធម្មធម្មំ បដិច្ច ន វិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ ន នេវវិបាកនវិបាកធម្មធម្មំ បដិច្ច ន នេវវិបាកនវិបាកធម្មធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

# នឧបាទិន្នុបាទានិយត្តិកំ

[១៦] ន ឧបាទិន្នុបាទានិយំ ធម្មំ បដិច្ច ន ឧបាទិន្នុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ ន អនុបាទិន្នុបាទានិយំ ធម្មំ បដិច្ច ន អនុបាទិន្នុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ ន អនុបាទិន្នអនុបាទានិយំ ធម្មំ បដិច្ច ន អនុបាទិន្នអនុបាទានិយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

ធម៌ ដែលមិនមែនសម្បយុត្តដោយអទុក្ខមសុខវេទនា អាស្រ័យ នូវធម៌ ដែលមិនមែនសម្បយុត្តដោយអទុក្ខមសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។

# នវិបាកត្តិកៈ

[១៥] ធម៌ មិនមែនជាវិបាក អាស្រ័យ នូវធម៌ មិនមែនជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ មិនមែនមានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាមិនមែនជាវិបាកទាំងមិនមែនមានវិបាកជាប្រក្រតី អាស្រ័យ នូវធម៌ មិនមែនជាមិនមែនជាវិបាកទាំងមិនមែនមានវិបាកជាប្រក្រី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

# នឧបាទិន្នុបាទានិយត្តិកៈ

[១៦] ធម៌ មិនមែនជាឧបាទិន្នុបាទានិយៈ អាស្រ័យ នូវធម៌ មិនមែនជាឧបាទិន្នុបាទានិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាអនុបាទិន្នុបាទានិយៈ អាស្រ័យ នូវធម៌ មិនមែនជាអនុបាទិន្នុបាទានិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាអនុបាទិន្នអនុបាទានិយៈ អាស្រ័យ នូវធម៌ មិនមែនជាអនុបាទិន្នអនុបាទានិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

# នសង្កិលិដ្ឋសង្កិលេសិកត្តិកំ

[១៧] ន សង្កិលិដ្ឋសង្កិលេសិកំ ធម្មំ បដិច្ច ន សង្កិលិដ្ឋសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុ-ប្បច្ចយា ។ ន អសង្កិលិដ្ឋសង្កិលេសិកំ ធម្មំ បដិច្ច ន អសង្កិលិដ្ឋសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេ-តុប្បច្ចយា ។ ន អសង្កិលិដ្ឋអសង្កិលេសិកំ ធម្មំ ប-ដិច្ច ន អសង្កិលិដ្ឋអសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

# នវិតក្កត្តិកំ

[១៨] ន សវិតក្កសវិចារំ ធម្មំ បដិច្ច ន សវិ-តក្កសវិចារោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ ន អវិតក្កវិចារមត្តំ ធម្មំ បដិច្ច ន អវិតក្កវិចារមត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ ន អវិតក្កអវិចារំ ធម្មំ បដិច្ច ន អវិតក្កអវិចារោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

# នសង្កិលិដ្ឋសង្កិលេសិកត្តិកៈ

[១៧] ធម៌ ដែលមិនមែនសៅហ្មងតែគួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវធម៌ ដែលមិនមែនសៅហ្មងតែគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ ដែលមិនមែនជាមិនសៅហ្មងតែគួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវធម៌ ដែលមិនមែនជាមិនសៅ-ហ្មងតែគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ ដែលមិនមែនជាមិនសៅហ្មងទាំងមិនគួរដល់សេចក្តីសៅហ្មង អា-ស្រ័យ នូវធម៌ ដែលមិនមែនជាមិនសៅហ្មងទាំងមិនគួរដល់សេចក្តីសៅ-ហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

# នវិតក្កត្តិកៈ

[១៨] ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិតក្កៈទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិតក្កៈទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ទើបកើតឡើង ព្រោះហេតុប្ប-ច្ច័យ ។ ធម៌ មិនមែនជាមិនមានវិតក្កៈមានត្រឹមតែវិចារៈ អាស្រ័យ នូវធម៌ មិនមែនជាមិនមានវិតក្កៈមានត្រឹមតែវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាមិនមានវិតក្កៈទាំងមិនមានវិចារៈ អា-ស្រ័យ នូវធម៌ មិនមែនជាមិនមានវិតក្កៈទាំងមិនមានវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

# នបីតិត្តិកំ

[១៩] ន បីតិសហគតំ ធម្មំ បដិច្ច ន បីតិសហគតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សុខសហគតំ ធម្មំ បដិច្ច . . . ន ឧបេក្ខាសហគតំ ធម្មំ បដិច្ច . . . ។

# នទស្សនត្តិកំ

[២០] ន ទស្សនេន បហាតព្វំ ធម្មំ បដិច្ច . . . ន ភាវនាយ បហាតព្វំ ធម្មំ បដិច្ច . . . ន នេវទស្ស-នេន ន ភាវនាយ បហាតព្វំ ធម្មំ បដិច្ច . . . ។

# នទស្សនេនបហាតព្វហេតុកត្តិកំ

[២១] ន ទស្សនេន បហាតព្វហេតុកំ ធម្មំ បដិច្ច . . . ន ភាវនាយ បហាតព្វហេតុកំ ធម្មំ បដិច្ច . . . ន នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកំ ធម្មំ បដិច្ច . . . ។

# នអាចយគាមិត្តិកំ

[២២] ន អាចយគាមឹ ធម្មំ បដិច្ច . . . ន អបច-យគាមឹ ធម្មំ បដិច្ច . . . ន នេវាចយគាមិនាបចយ-គាមឹ ធម្មំ បដិច្ច . . . ។

# នបីតិត្តិកៈ

[១៩] *ធម៌ មិនមែនប្រកបដោយបីតិ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយសុខ . . . អាស្រ័យ នូវធម៌ មិនមែនប្រកបដោយឧបេក្ខា . . . ។*

# នទស្សនត្តិកៈ

[២០] *អាស្រ័យ នូវធម៌ មិនមែនត្រូវលះដោយទស្សនៈ . . . អាស្រ័យ នូវធម៌ មិនមែនត្រូវលះដោយភាវនា . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមែនត្រូវលះដោយទស្សនៈ និងមិនមែនត្រូវលះដោយភាវនា . . . ។*

# នទស្សនេនបហាតព្វហេតុកត្តិកៈ

[២១] *អាស្រ័យ នូវធម៌ មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ . . . អាស្រ័យ នូវធម៌ មានហេតុដែលមិនមែនត្រូវលះដោយភាវនា . . . អាស្រ័យ នូវធម៌ មានហេតុដែលមិនមែនជាមិនមែនត្រូវលះដោយទស្សនៈ និងមិនមែនត្រូវលះដោយភាវនា. . . ។*

# នអាចយគាមិត្តិកៈ

[២២] *អាស្រ័យ នូវធម៌ មិនមែនដល់នូវការសន្សំកពូនឡើង . . . អាស្រ័យ នូវធម៌ មិនមែនជាមិនដល់នូវការសន្សំកពូនឡើង. . . អាស្រ័យ នូវធម៌ មិនមែនជាមិនមែនដល់នូវការសន្សំកពូនឡើងនិងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង . . . ។*

# នសេក្ខត្តិកំ

[២៣] ន សេក្ខំ ធម្មំ បដិច្ច . . . ន អសេក្ខំ ធម្មំ បដិច្ច . . . ន នេវសេក្ខានាសេក្ខំ ធម្មំ បដិច្ច . . . ។

# នបរិត្តត្តិកំ

[២៤] ន បរិត្តំ ធម្មំ បដិច្ច . . . នមហគ្គតំ ធម្មំ បដិច្ច . . . ន អប្បមាណំ ធម្មំ បដិច្ច . . . ។

# នបរិត្តារម្មណត្តិកំ

[២៥] នបរិត្តារម្មណំ ធម្មំ បដិច្ច . . . ន មហគ្គតារម្មណំ ធម្មំ បដិច្ច . . . ន អប្បមាណារម្មណំ ធម្មំ បដិច្ច . . . ។

# នហីនត្តិកំ

[២៦] ន ហីនំ ធម្មំ បដិច្ច . . . ន មជ្ឈិមំ ធម្មំ បដិច្ច . . . ន បណីតំ ធម្មំ បដិច្ច . . . ។

# នមិច្ឆត្តត្តិកំ

[២៧] ន មិច្ឆត្តនិយតំ ធម្មំ បដិច្ច . . . ន សម្មត្តនិយតំ ធម្មំ បដិច្ច . . . ន អនិយតំ ធម្មំ បដិច្ច . . . ។

# នសេក្ខត្តិកៈ

[២៣] *អាស្រ័យ នូវធម៌ មិនមែនជាសេក្ខៈ . . . អាស្រ័យ នូវធម៌ មិនមែនជាអសេក្ខៈ . . . អាស្រ័យ នូវធម៌ មិនមែនជានេវ-សេក្ខានាសេក្ខៈ . . . ។*

# នបរិត្តត្តិកៈ

[២៤] *អាស្រ័យ នូវធម៌ មិនមែនមានសភាពតូចថ្មារ . . . អាស្រ័យ នូវធម៌ មិនមែនដល់នូវសភាពធំ . . . អាស្រ័យ នូវធម៌ មិនមែនមានប្រមាណមិនបាន . . . ។*

# នបរិត្តារម្មណត្តិកៈ

[២៥] *អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍តូចថ្មារ . . . អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍ដល់នូវសភាពធំ . . . អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍ប្រមាណមិនបាន . . . ។*

# នហីនត្តិកៈ

[២៦] *អាស្រ័យ នូវធម៌ មិនមែនថោកទាប . . . អាស្រ័យ នូវធម៌ មិនមែនជាកណ្តាល . . . អាស្រ័យ នូវធម៌ មិនមែនឧត្តម . . . ។*

# នមិច្ឆត្តត្តិកៈ

[២៧] *អាស្រ័យ នូវធម៌ មិនមែនមានសភាពខុសនិងទៀង . . . អាស្រ័យ នូវធម៌ មិនមែនមានសភាពត្រូវនិងទៀង . . . អាស្រ័យ នូវធម៌ មិនមែនជាមិនទៀង. . . ។*

បច្ចនីយត្តិកប្បដ្ឋានំ

# នមគ្គារម្មណត្តិកំ

[២៨] ន មគ្គារម្មណំ ធម្មំ បដិច្ច . . . ន មគ្គហេតុកំ ធម្មំ បដិច្ច . . . ន មគ្គាធិបតឹ ធម្មំ បដិច្ច . . . ។

# នឧប្បន្នត្តិកំ

[២៩] ន អនុប្បន្នំ ធម្មំ បដិច្ច ន អនុប្បន្នោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អនុប្បន្នំ ធម្មំ បដិច្ច ន ឧប្បាទី ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អនុប្បន្នំ ធម្មំ បដិច្ច ន អនុប្បន្នោ ច ន ឧប្បាទី ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន ឧប្បាទឹ ធម្មំ បដិច្ច ន ឧប្បាទី ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ឧប្បាទឹ ធម្មំ បដិច្ច ន អនុប្បន្នោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ឧប្បាទឹ ធម្មំ បដិច្ច ន អនុប្បន្នោ ច ន ឧប្បាទី ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន អនុប្បន្នញ្ច ន ឧប្បាទិញ្ច ធម្មំ បដិច្ច ន អនុប្បន្នោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

# នមគ្គារម្មណត្តិកៈ

[២៨] *អាស្រ័យ នូវធម៌ មិនមែនមានមគ្គជាអារម្មណ៍ . . . អាស្រ័យ នូវធម៌ មិនមែនមានមគ្គជាហេតុ . . . អាស្រ័យ នូវធម៌ មិនមែនមានមគ្គជាអធិបតិ . . . ។*

# នឧប្បន្នត្តិកៈ

[២៩] *ធម៌ មិនមែនជាមិនទាន់កើតឡើងហើយ អាស្រ័យ នូវធម៌ មិនមែនជាមិនទាន់កើតឡើងហើយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនកើតឡើង អាស្រ័យ នូវធម៌ មិនមែនជាមិនទាន់កើតឡើងហើយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនទាន់កើតឡើងហើយក្តី មិនមែនកើតឡើងក្តី អាស្រ័យ នូវធម៌ មិនមែនជាមិនទាន់កើតឡើងហើយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនកើតឡើង អាស្រ័យ នូវធម៌ មិនមែនកើតឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនទាន់កើតឡើងហើយ អាស្រ័យ នូវធម៌ មិនមែនកើតឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនទាន់កើតឡើងហើយក្តី មិនមែនកើតឡើងក្តី អាស្រ័យ នូវធម៌ មិនមែនកើតឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាមិនទាន់កើតឡើងហើយ អាស្រ័យ នូវធម៌ មិនមែនជាមិនទាន់កើតឡើងហើយផង មិនមែនកើតឡើងផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ*

ន អនុប្បន្នញ្ច ន ឧប្បាទិញ្ច ធម្មំ បដិច្ច ន ឧប្បាទី ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អនុប្បន្នញ្ច ន ឧប្បាទិញ្ច ធម្មំ បដិច្ច ន អនុប្បន្នោ ច ន ឧប្បាទី ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។

## នអតីតត្តិកំ

[៣០] ន អតីតំ ធម្មំ បដិច្ច ន អតីតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[៣១] ន អតីតោ ធម្មោ ន អតីតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ន អតីតោ ធម្មោ ន អនាគតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ន អតីតោ ធម្មោ ន អតីតស្ស ច ន អនាគតស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ ន អនាគតោ ធម្មោ ន អនាគតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ន អនាគតោ ធម្មោ ន អតីតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ន អនាគតោ ធម្មោ ន អតីតស្ស ច ន អនាគតស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ ន អតីតោ ច ន អនាគតោ ច ធម្មា ន អតីតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ន អតីតោ ច ន អនាគតោ ច ធម្មា ន អនាគតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ

ធម៌ មិនមែនកើតឡើង អាស្រ័យ នូវធម៌ មិនមែនជាមិនទាន់កើតឡើងហើយផង មិនមែនកើតឡើងផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនទាន់កើតឡើងហើយក្តី មិនមែនកើតឡើងក្តី អាស្រ័យ នូវធម៌ មិនមែនជាមិនទាន់កើតឡើងហើយផង មិនមែនកើតឡើងផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

## នអតីតត្តិកៈ

[៣០] ធម៌ មិនមែនជាអតីត អាស្រ័យ នូវធម៌ មិនមែនជាអតីត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៣១] ធម៌ មិនមែនជាអតីត ជាបច្ច័យ នៃធម៌ មិនមែនជាអតីត ដោយហេតុប្បច្ច័យ ធម៌ មិនមែនជាអតីត ជាបច្ច័យ នៃធម៌ មិនមែនជាអនាគត ដោយហេតុប្បច្ច័យ ធម៌ មិនមែនជាអតីត ជាបច្ច័យ នៃធម៌ មិនមែនជាអតីតផង មិនមែនជាអនាគតផង ដោយហេតុប្បច្ច័យ ។ ធម៌ មិនមែនជាអនាគត ជាបច្ច័យ នៃធម៌ មិនមែនជាអនាគត ដោយហេតុប្បច្ច័យ ធម៌ មិនមែនជាអនាគត ជាបច្ច័យ នៃធម៌ មិនមែនជាអតីត ដោយហេតុប្បច្ច័យ ធម៌ មិនមែនជាអនាគត ជាបច្ច័យ នៃធម៌ មិនមែនជាអតីតផង មិនមែនជាអនាគតផង ដោយហេតុប្បច្ច័យ ។ ធម៌ មិនមែនជាអតីតផង មិនមែនជាអនាគតផង ជាបច្ច័យ នៃធម៌ មិនមែនជាអតីត ដោយហេតុប្បច្ច័យ ធម៌ មិនមែនជាអតីតផង មិនមែនជាអនាគតផង ជាបច្ច័យ នៃធម៌ មិនមែនជាអនាគត ដោយហេតុប្បច្ច័យ

ន អតីតោ ច ន អនាគតោ ច ធម្មា ន អតីតស្ស ច ន អនាគតស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

## នអតីតារម្មណត្តិកំ

[៣២] ន អតីតារម្មណំ ធម្មំ បដិច្ច . . . ន អនា-គតារម្មណំ ធម្មំ បដិច្ច . . . ន បច្ចុប្បន្នារម្មណំ ធម្មំ បដិច្ច . . . ។

## នអជ្ឈត្តត្តិកំ

[៣៣] ន អជ្ឈត្តំ ធម្មំ បដិច្ច ន អជ្ឈត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ ន ពហិទ្ធា ធម្មំ បដិច្ច ន ពហិទ្ធា ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

## នអជ្ឈត្តារម្មណត្តិកំ

[៣៤] ន អជ្ឈត្តារម្មណំ ធម្មំ បដិច្ច ន អជ្ឈត្តា-រម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អជ្ឈត្តា-រម្មណំ ធម្មំ បដិច្ច ន ពហិទ្ធារម្មណោ ធម្មោ ឧប្ប-ជ្ជតិ ហេតុប្បច្ចយា ។ ន ពហិទ្ធារម្មណំ ធម្មំ បដិច្ច ន ពហិទ្ធារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

*ធម៌ មិនមែនជាអតីតផង មិនមែនជាអនាគតផង ជាបច្ច័យ នៃធម៌ មិនមែនជាអតីតផង មិនមែនជាអនាគតផង ដោយហេតុប្បច្ច័យ ។*

# នអតីតារម្មណត្តិកៈ

[៣២] *អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍ជាអតីត . . . អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍ជាអនាគត . . . អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍ជាបច្ចុប្បន្ន . . . ។*

# នអជ្ឈត្តត្តិកៈ

[៣៣] *ធម៌ មិនមែនជាខាងក្នុង អាស្រ័យ នូវធម៌ មិនមែនជាខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាខាងក្រៅ អាស្រ័យ នូវធម៌ មិនមែនជាខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។*

# នអជ្ឈត្តារម្មណត្តិកៈ

[៣៤] *ធម៌ មិនមែនមានអារម្មណ៍ជាខាងក្នុង អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍ជាខាងក្នុង ទើបកើតឡើង ព្រោះហេតុ-ប្បច្ច័យ ធម៌ មិនមែនមានអារម្មណ៍ជាខាងក្រៅ អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍ជាខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនមានអារម្មណ៍ជាខាងក្រៅ អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍ជាខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ*

ន ពហិទ្ធារម្មណំ ធម្មំ បដិច្ច ន អជ្ឈត្តារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

## នសនិទស្សនត្តិកំ

[៣៨] ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន សនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្ប-ច្ចយា ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន អនិ-ទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន អនិទស្សន-អប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សនិ-ទស្សនសប្បដិឃំ ធម្មំ បដិច្ច ន សនិទស្សនសប្បដិ-ឃោ ច ន អនិទស្សនអប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ

ធម៌ មិនមែនមានអារម្មណ៍ជាខាងក្នុង អាស្រ័យ នូវធម៌ មិនមែនមានអារម្មណ៍ជាខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

# នសនិទស្សនត្តិកៈ

[៣៥] ធម៌ មិនមែនប្រកបដោយការឃើញតែប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមែនការឃើញតែប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រកបដោយការឃើញតែប្រកបដោយការប៉ះពាល់ក្តី មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ក្តី អាស្រ័យ នូវធម៌ មិនមែនប្រកបដោយការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង

ហេតុប្បច្ចយា ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន អនិទស្សនសប្បដិឃោ ច ន អនិទស្សនអប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន សនិទស្សនសប្បដិឃោ ច ន អនិទស្សនសប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។

[៣៦] ន អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន អនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន សនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន អនិទស្សនអប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន សនិទស្សនសប្បដិឃោ ច ន អនិទស្សនអប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា

ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ក្តី មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ក្តី អាស្រ័យ នូវធម៌ មិនមែនប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ក្តី មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ក្តី អាស្រ័យ នូវធម៌ មិនមែនប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៣៦] ធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះ-ពាល់ អាស្រ័យ នូវធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះ-ពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ក្តី មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ក្តី អាស្រ័យ នូវធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ន អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន អនិទស្សន-សប្បដិឃោ ច ន អនិទស្សនអប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន សនិទស្សនសប្បដិឃោ ច ន អនិទស្សន-អប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។

[៣៧] ន អនិទស្សនអប្បដិឃំ ធម្មំ បដិច្ច ន អ-និទស្សនអប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អនិទស្សនអប្បដិឃំ ធម្មំ បដិច្ច ន សនិទស្សន-សប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អនិ-ទស្សនអប្បដិឃំ ធម្មំ បដិច្ច ន អនិទស្សនសប្បដិ-ឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឆ ។

[៣៨] ន សនិទស្សនសប្បដិឃញ្ច ន អនិទស្ស-នអប្បដិឃញ្ច ធម្មំ បដិច្ច ន សនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឆ ។

ធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ក្តី មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ក្តី អាស្រ័យ នូវធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ក្តី មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ក្តី អាស្រ័យ នូវធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះ-ពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៣៧] ធម៌ មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះ-ពាល់ អាស្រ័យ នូវធម៌ មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ ធម៌ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[៣៨] ធម៌ មិនមែនប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយការឃើញទាំងប្រ-កបដោយការប៉ះពាល់ផង មិនមែនជាមិនមានការឃើញទាំងមិនមានការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

១៩

បច្ចនីយត្តិកប្បដ្ឋានំ

[៣៩] ន សនិទស្សនសប្បដិឃញ្ច ន អនិទស្ស-នសប្បដិឃញ្ច ធម្មំ បដិច្ច ន សនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឆ ។

[៤០] ហេតុយា តីស អវិគតេ តីស ។

យថា កុសលត្តិកេ សហជាតវារម្បិ បច្ចយ-វារម្បិ និស្សយវារម្បិ សំសដ្ឋវារម្បិ សម្បយុត្ត-វារម្បិ បញ្ហាវារម្បិ គណិតំ ឯវំ គណេតព្វំ ។

បច្ចនីយកប្បដ្ឋានំ និដ្ឋិតំ ។

បច្ចនីយត្តិកប្បដ្ឋាន

[៣៩] ធម៌ មិនមែនប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយការឃើញទាំងប្រ-កបដោយការប៉ះពាល់ផង មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[៤០] ក្នុងហេតុប្បច្ច័យ មានវារៈ ៣០ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣០ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បញ្ហាវារៈក្តី ដែលយើងរាប់ហើយ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិត គប្បីរាប់ យ៉ាងនោះចុះ ។

ចប់ បច្ចនីយត្តិកប្បដ្ឋាន ។

# បច្ចនីយទុកប្បដ្ឋានំ

## នហេតុទុកំ

[៤១] ន ហេតុំ ធម្មំ បដិច្ច ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នហេតុំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ បដិច្ច . . . បដិសន្ធិក្ខណេ . . . យាវ មហាភូតា ។ ន ហេតុំ ធម្មំ បដិច្ច ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតូ ខន្ធេ បដិច្ច . . . ហេតុ-ប្បដិសន្ធិ ។ ន ហេតុំ ធម្មំ បដិច្ច ន ហេតុ ច ន ន ហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន នហេតុំ ធម្មំ បដិច្ច ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន នហេតុំ ធម្មំ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន នហេតុំ ធម្មំ បដិច្ច ន ហេតុ ច ន នហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។

# បច្ចនីយទុកប្បដ្ឋាន

## នហេតុទុកៈ

[៤១] ធម៌ មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវខន្ធ ១ មិនមែនជាហេតុ អាស្រ័យ នូវខន្ធ ២ . . . ក្នុងខណៈនៃបដិសន្ធិ . . . ដរាបដល់ពួកមហាភូត ។ ធម៌ មិនមែនជាមិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អាស្រ័យ នូវពួកខន្ធ មិនមែនជាហេតុ . . . ហេតុប្បដិសន្ធិ ។ ធម៌ មិនមែនជាហេតុក្តី មិនមែនជាមិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាមិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុក្តី មិនមែនជាមិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

ន ហេតុញ្ច ន នហេតុញ្ច ធម្មំ បដិច្ច ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុញ្ច ន នហេតុញ្ច ធម្មំ បដិច្ច ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុញ្ច ន នហេតុញ្ច ធម្មំ បដិច្ច ន ហេតុ ច ន នហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។

[៤២] ហេតុយា នវ អារម្មណេ នវ អវិគតេ នវ ។

សហជាតវារម្បិ សម្បយុត្តវារម្បិ បដិច្ចវារសទិសំ ឯវំ វិត្ថារេតព្វំ ។

[៤៣] ន នហេតុ ធម្មោ ន នហេតុស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ន នហេតុ ធម្មោ ន ហេ-តុស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ន នហេតុ ធម្មោ ន ហេតុស្ស ច ន នហេតុស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

[៤៤] ន ហេតុ ធម្មោ ន ហេតុស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ន ហេតុ ធម្មោ ន ន-ហេតុស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ

ធម៌ មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុផង មិនមែនជាមិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុផង មិនមែនជាមិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុក្តី មិនមែនជាមិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាហេតុផង មិនមែនជាមិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤២] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី

ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

[៤៣] ធម៌ មិនមែនជាមិនមែនជាហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាមិនមែនជាហេតុ ដោយហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមែនជាហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុ ដោយហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមែនជាហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុផង មិនមែនជាមិនមែនជាហេតុផង ដោយហេតុប្បច្ច័យ ។

[៤៤] ធម៌ មិនមែនជាហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ

ន ហេតុ ធម្មោ ន ហេតុស្ស ច ន នហេតុស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។ ន នហេតុ ធម្មោ ន នហេតុស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ន នហេតុ ធម្មោ ន ហេតុស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ន នហេតុ ធម្មោ ន-ហេតុស្ស ច ន នហេតុស្ស ច ធម្មស្ស អារម្មណ-ប្បច្ចយេន បច្ចយោ ។ នហេតុ ច ន នហេតុ ច ធម្មា ន ហេតុស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ច-យោ ន ហេតុ ច ន នហេតុ ច ធម្មា ន នហេតុស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ន ហេតុ ច ន នហេតុ ច ធម្មា ន ហេតុស្ស ច ន នហេតុស្ស ច ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

[៤៨] ហេតុយា តីណិ អារម្មណេ នវ អវិ-គតេ នវ ។

យថា កុសលត្តិកេ បញ្ហាវារំ

ឯវំ វិត្ថារេតព្វំ ។

ធម៌ មិនមែនជាហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុផង មិនមែនជាមិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ ។ ធម៌ មិនមែនជាមិនមែនជាហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាមិនមែនជាហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាមិនមែនជាហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុផង មិនមែនជាមិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ ។ ធម៌ មិនមែនជាហេតុក្តី មិនមែនជាមិនមែនជាហេតុក្តី ជាបច្ច័យ នៃធម៌ មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាហេតុក្តី មិនមែនជាមិនមែនជាហេតុក្តី ជាបច្ច័យ នៃធម៌ មិនមែនជាមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាហេតុក្តី មិនមែនជាមិនមែនជាហេតុក្តី ជាបច្ច័យ នៃធម៌ មិនមែនជាហេតុផង មិនមែនជាហេតុផង ដោយអារម្មណប្បច្ច័យ ។

[៤៥] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

បច្ចនីយទុកប្បដ្ឋានំ

# នសហេតុកទុកំ

[៤៦] ន សហេតុកំ ធម្មំ បដិច្ច ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិចិកិច្ឆាសហគតំ ឧទ្ធច្ចសហគតំ មោហំ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ទ្វេ មហាភូតេ បដិច្ច ទ្វេ មហាភូតា មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ។ ន សហេតុកំ ធម្មំ បដិច្ច ន-អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិចិកិច្ឆាសហគតំ ឧទ្ធច្ចសហគតំ មោហំ បដិច្ច សម្បយុត្តកា ខន្ធា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច សហេតុកា ខន្ធា ។ ន សហេតុកំ ធម្មំ បដិច្ច ន សហេតុកោ ច ន អហេតុកោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន អហេតុកំ ធម្មំ បដិច្ច ន-អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ ន សហេតុកញ្ច ន អហេតុកញ្ច ធម្មំ បដិច្ច ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សហេតុកញ្ច ន អហេតុកញ្ច ធម្មំ បដិច្ច ន អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

បច្ចនីយទុកប្បដ្ឋាន

# នសហេតុកទុកៈ

[៤៦] ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ មហាភូត ៣ អាស្រ័យ នូវមហាភូត ១ មហាភូត ២ អាស្រ័យ នូវមហាភូត ២ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវពួកមហាភូត ។ ធម៌ មិនមែនជាមិនមានហេតុ អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យ នូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពួកសហេតុកក្ខន្ធ អាស្រ័យ នូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុក្តី មិនមែនជាមិនមានហេតុក្តី អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាមិនមានហេតុ អាស្រ័យ នូវធម៌ មិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាមិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមានហេតុ អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាមិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ន សហេតុកញ្ច ន អហេតុកញ្ច ធម្មំ បដិច្ច ន-
សហេតុកោ ច ន អហេតុកោ ច ធម្មា ឧប្បជ្ជន្តិ
ហេតុប្បច្ចយា ។

[៤៧] ហេតុយា នវ អារម្មណេ ឆ អវិគតេ នវ ។

សហជាតវារម្បិ សម្បយុត្តវារម្បិ បដិច្ច-
វារសទិសំ ឯវំ វិត្ថារេតព្វំ ។

[៤៨] ន សហេតុកោ ធម្មោ ន សហេតុកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ន សហេតុកោ ធម្មោ ន អហេតុកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ន សហេតុកោ ធម្មោ ន សហេតុកស្ស ច ន អហេតុកស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ ន អហេតុកោ ធម្មោ ន អហេតុកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។

[៤៩] ន សហេតុកោ ធម្មោ ន សហេតុកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

[៥០] ហេតុយា ឆ អារម្មណេ នវ អវិគតេ នវ ។

យថា កុសលត្តិកេ បញ្ហាវារំ

ឯវំ វិត្ថារេតព្វំ ។

ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុក្តី មិនមែនជាមិនមានហេតុក្តី អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាមិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៧] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ច-
វារៈដែរ បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

[៤៨] ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យ នៃធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយហេតុប្បច្ច័យ ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាមិនមានហេតុ ដោយហេតុប្បច្ច័យ ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យ នៃធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាមិនមានហេតុផង ដោយហេតុប្បច្ច័យ ។ ធម៌ មិនមែនជាមិនមានហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាមិនមានហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[៤៩] ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យ នៃធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ ។

[៥០] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

# នហេតុសម្បយុត្តទុកំ

[៤១] ន ហេតុសម្បយុត្តំ ធម្មំ បដិច្ច ន ហេតុសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុសម្បយុត្តំ ធម្មំ បដិច្ច ន ហេតុវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុសម្បយុត្តំ ធម្មំ បដិច្ច ន ហេតុសម្បយុត្តោ ច ន ហេតុវិប្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន ហេតុវិប្បយុត្តំ ធម្មំ បដិច្ច ន ហេតុវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុវិប្បយុត្តំ ធម្មំ បដិច្ច ន ហេតុសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុវិប្បយុត្តំ ធម្មំ បដិច្ច ន ហេតុសម្បយុត្តោ ច នហេតុវិប្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។

[៤២] ហេតុយា នវ អារម្មណេ ឆ អវិគតេ នវ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ វិត្ថារេតព្វំ ។

# នហេតុសហេតុកទុកំ

[៤៣] ន ហេតុញ្ចេវ ន អហេតុកញ្ច ធម្មំ បដិច្ច ន ហេតុចេវ ន អហេតុកោ ច ធម្មោ

# នហេតុសម្បយុត្តទុកៈ

[៥១] ធម៌ មិនមែនប្រកបដោយហេតុ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រាសចាកហេតុ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រកបដោយហេតុក្តី មិនមែនប្រាសចាកហេតុក្តី អាស្រ័យ នូវធម៌ មិនមែនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនប្រាសចាកហេតុ អាស្រ័យ នូវធម៌ មិនមែនប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រកបដោយហេតុ អាស្រ័យ នូវធម៌ មិនមែនប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រកបដោយហេតុក្តី មិនមែនប្រាសចាកហេតុក្តី អាស្រ័យ នូវធម៌ មិនមែនប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៥២] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី បណ្ឌិត
គប្បីឲ្យពិស្តារ គ្រប់បច្ច័យទាំងអស់ចុះ ។

# នហេតុសហេតុកទុកៈ

[៥៣] ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ

ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុញ្ចេវ ន អហេតុកញ្ច ធម្មំ បដិច្ច ន អហេតុកោ ចេវ ន នហេតុ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុញ្ចេវ ន អហេតុកញ្ច ធម្មំ បដិច្ច ន ហេតុ ចេវ ន អហេតុកោ ច ន អហេតុកោ ចេវ ន នហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន អហេតុកញ្ចេវ ន នហេតុញ្ច ធម្មំ បដិច្ច ន អហេតុកោចេវ ន នហេតុ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អហេតុកញ្ចេវ ន នហេតុញ្ច ធម្មំ បដិច្ច នហេតុ ចេវ ន អហេតុកោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អហេតុកញ្ចេវ ន នហេតុញ្ច ធម្មំ បដិច្ច ន ហេតុចេវ ន អហេតុកោ ច ន អហេតុកោ ចេវ ន នហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន ហេតុញ្ចេវ ន អហេតុកញ្ច ន អហេតុកញ្ចេវ ន នហេតុញ្ច ធម្មំ បដិច្ច ន ហេតុ ចេវ ន អហេតុកោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមែនហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមែនហេតុក្តី មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមានជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ អាស្រ័យ នូវធម៌ មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុក្តី មិនមែនជាមិនមែនហេតុ ទាំងមិនមែនជាមិនមានហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុផង មិនមែនជាមិនមានហេតុ ទាំងមិនមែនជាមិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

២៧

បច្ចនីយទុកប្បដ្ឋានំ

[៥៤] ហេតុយា នវ អារម្មណេ នវ អវិគតេ នវ ។ សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ វិត្ថារោ ។

## នហេតុហេតុសម្បយុត្តទុកំ

[៥៥] ន ហេតុញ្ចេវ ន ហេតុវិប្បយុត្តញ្ច ធម្មំ បដិច្ច ន ហេតុចេវ ន ហេតុវិប្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុញ្ចេវ ន ហេតុវិប្បយុត្តញ្ច ធម្មំ បដិច្ច ន ហេតុវិប្បយុត្តោ ចេវ ន នហេតុ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុញ្ចេវ ន ហេតុវិប្បយុត្តញ្ច ធម្មំ បដិច្ច ន ហេតុចេវ ន ហេតុវិប្បយុត្តោច ន ហេតុវិប្បយុត្តោ ចេវ ន នហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន ហេតុវិប្បយុត្តញ្ចេវ ន នហេតុញ្ច ធម្មំ បដិច្ច នហេតុវិប្បយុត្តោ ចេវ ន នហេតុ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុវិប្បយុត្តញ្ចេវ នហេតុញ្ច ធម្មំ បដិច្ច ន ហេតុ ចេវ ន ហេតុវិប្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

[៥២] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី មាន
សេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

# នហេតុហេតុសម្បយុត្តទុកៈ

[៥៥] ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រាសចាកហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រាសចាកហេតុក្តី មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រាសចាកហេតុ អាស្រ័យ នូវធម៌ មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ន ហេតុវិប្បយុត្តញ្ចេវ ន នហេតុញ្ច ធម្មំ បដិច្ច ន-
ហេតុ ចេវ ន ហេតុវិប្បយុត្តោ ច ន ហេតុវិប្បយុត្តោ ចេវ
ន នហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។
[៤៦] ហេតុយា នវ អវិគតេ នវ សព្វត្ថ វិត្ថារោ ។

# នហេតុនសហេតុកទុកំ

[៤៧] នហេតុំ ន សហេតុកំ ធម្មំ បដិច្ច ន-
ហេតុ ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ច-
យា ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ។
នហេតុំ ន សហេតុកំ ធម្មំ បដិច្ច ន ហេតុ ន អហេតុ-
កោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា បដិសន្ធិក្ខណេ
វត្ថុំ បដិច្ច ន ហេតុ ន សហេតុកា ខន្ធា ។ ន ហេតុំ
ន សហេតុកំ ធម្មំ បដិច្ច ន ហេតុ ន សហេតុកោ
ច នហេតុ ន អហេតុកោ ច ធម្មា ឧប្បជ្ជន្តិ ហេ-
តុប្បច្ចយា ។ ន ហេតុំ ន អហេតុកំ ធម្មំ បដិច្ច
នហេតុ ន អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រាសចាកហេតុក្តី មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនប្រាសចាកហេតុ ទាំងមិនមែនជាមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៩៦] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

# នហេតុនសហេតុកទុកៈ

[៩៧] ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ មហាភូត ៣ អាស្រ័យ នូវមហាភូត ១ ។ ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកខន្ធមិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យ នូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។ ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុក្តី មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

២៩

បច្ចនីយទុកប្បដ្ឋានំ

ន ហេតុំ ន អហេតុកំ ធម្មំ បដិច្ច នហេតុ ន សហេ-តុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុំ ន អហេតុកំ ធម្មំ បដិច្ច នហេតុ ន សហេតុកោ ច ន ហេតុ ន អហេតុកោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ នហេតុំ ន សហេតុកញ្ច ន ហេតុំ ន អហេតុកញ្ច ធម្មំ បដិច្ច ន ហេតុ ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុំ ន សហេតុ-កញ្ច ន ហេតុំ ន អហេតុកញ្ច ធម្មំ បដិច្ច ន ហេតុ ន អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុំ ន សហេតុកញ្ច ន ហេតុំ ន អហេតុកញ្ច ធម្មំ បដិច្ច ន ហេតុ ន សហេតុកោ ច ន ហេតុ ន អហេតុ-កោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។

[៤៨] ហេតុយា នវ អារម្មណេ នវ អវិគតេ នវ ។

សហជាតវារម្បិ សម្បយុត្តវារម្បិ

បដិច្ចវារសទិសំ ។

*ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុក្តី មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុក្តី អាស្រ័យនូវធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុក្តី មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។*

*[៥៨] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។*

*សហជាតវារៈក្តី សម្បយុត្តវារៈ*

*ក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។*

[៥៩] នហេតុ ន សហេតុកោ ធម្មោ នហេតុស្ស ន សហេតុកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ នហេតុ ន សហេតុកោ ធម្មោ នហេតុស្ស ន អហេតុកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទ្វេ ។ នហេតុ ន អហេតុកោ ធម្មោ នហេតុស្ស ន អហេតុកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ នហេតុ ន អហេតុកោ ធម្មោ នហេតុស្ស ន សហេតុកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទ្វេ ។

[៦០] អារម្មណេ ចត្តារិ អវិគតេ ចត្តារិ ។

បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

# នសប្បច្ចយទុកំ

[៦១] ន អប្បច្ចយំ ធម្មំ បដិច្ច ន អប្បច្ចយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[៦២] ហេតុយា ឯកំ សព្វត្ថ វិត្ថារោ ។

[៥៩] ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ២ ។ ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ ដោយអារម្មណប្បច្ច័យ ធម៌ មិនមែនជាហេតុ ទាំងមិនមែនជាមិនមានហេតុ ជាបច្ច័យ នៃធម៌ មិនមែនជាហេតុ ទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ២ ។

[៦០] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

បញ្ហាវារៈ បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនេះផងចុះ ។

# នសប្បច្ចយទុកៈ

[៦១] ធម៌ មិនមែនជាមិនមានបច្ច័យ អាស្រ័យ នូវធម៌ មិនមែនជាមិនមានបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៦២] ក្នុងហេតុប្បច្ច័យ មានវារៈ ១ សេចក្តីពិស្តារ មានក្នុងបច្ច័យទាំងអស់ ។

[៦៣] ន អប្បច្ចយោ ធម្មោ ន អប្បច្ចយស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

[៦៤] ន សប្បច្ចយោ ធម្មោ ន អប្បច្ចយស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

[៦៥] ហេតុយា ឯកំ អារម្មណេ ទ្វេ សព្វត្ថ វិត្ថារោ ។

## នសង្ខតទុកំ

[៦៦] ន អសង្ខតំ ធម្មំ បដិច្ច ន អសង្ខតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[៦៧] ហេតុយា ឯកំ សប្បច្ចយទុកសទិសំ ។

## នសនិទស្សនទុកំ

[៦៨] ន សនិទស្សនំ ធម្មំ បដិច្ច ន សនិទស្សនោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សនិទស្សនំ ធម្មំ បដិច្ច ន អនិទស្សនោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សនិទស្សនំ ធម្មំ បដិច្ច ន សនិទស្សនោ ច ន អនិទស្សនោ ច ធម្មោ ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។

បច្ចនីយទុកប្បដ្ឋាន

[៦៣] ធម៌ មិនមែនជាមិនមានបច្ច័យ ជាបច្ច័យ នៃធម៌ មិនមែនជាមិនមានបច្ច័យ ដោយហេតុប្បច្ច័យ ។

[៦៤] ធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ជាបច្ច័យ នៃធម៌ មិនមែនជាមិនមានបច្ច័យ ដោយអារម្មណប្បច្ច័យ ។

[៦៥] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ សេចក្តីពិស្តារ មានក្នុងបច្ច័យទាំងអស់ ។

# នសង្ខតទុកៈ

[៦៦] ធម៌ ដែលមិនមែនបច្ច័យមិនប្រជុំតាក់តែង អាស្រ័យនូវធម៌ ដែលមិនមែនបច្ច័យមិនប្រជុំតាក់តែង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៦៧] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ដូចគ្នានឹងសប្បច្ចយទុកៈ ។

# នសនិទស្សនទុកៈ

[២៤២] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

បណ្ឌិត គប្បីញុំាងបញ្ហាវារៈ ឲ្យពិស្តារ យ៉ាងនេះចុះ ។

បច្ចនីយទុកត្តិកប្បដ្ឋានំ

[២៤៣] ន ហេតុំ ន អធិបតិបច្ចយជិយំ ធម្មំ បដិច្ច ន ហេតុ ន អធិបតិបច្ចយជិយោ ធម្មោ ឧប្ប-ជ្ជតិ ហេតុប្បច្ចយា ។

[២៤៤] ហេតុយា ឯកំ សព្វត្ថ វិត្ថារោ ។

# នសហេតុកទុកនកុសលត្តិកំ

[២៤៥] ន សហេតុកំ ន កុសលំ ធម្មំ បដិច្ច ន សហេតុកោ ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេ-តុប្បច្ចយា វិចិកិច្ឆាសហគតំ ឧទ្ធច្ចសហគតំ មោហំ បដិច្ច ចិត្តសមុដ្ឋានំ រូបំ ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ។ ន សហេតុកំ ន កុសលំ ធម្មំ បដិច្ច ន អហេតុកោ ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា វិចិកិច្ឆាសហគតំ ឧទ្ធច្ច-សហគតំ មោហំ បដិច្ច សម្បយុត្តកា ខន្ធា បដិសន្ធិក្ខណេ វត្ថុំ បដិច្ច សហេតុកា ខន្ធា ។

បច្ចនីយទុកត្តិកបដ្ឋាន

[២៤៣] ធម៌ មិនមែនជាហេតុ មិនមែនជាមិនមានការឃើញនិងមិនមានការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាហេតុ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[២៤៤] ក្នុងហេតុប្បច្ច័យ មានវារៈ ១ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

# នសហេតុកទុកនកុសលត្តិកៈ

[២៤៥] ធម៌ មិនមែនជាសហេតុកៈ (មិនមែនប្រព្រឹត្តទៅជាមួយនឹងហេតុ) មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាសហេតុកៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប អាស្រ័យ នូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ មហាភូត ៣ អាស្រ័យ នូវមហាភូត ១ ។ ធម៌ មិនមែនជាអហេតុកៈ (មិនមែនជាមិនមានហេតុ) មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាសហេតុកៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ពួកសម្បយុត្តកក្ខន្ធ អាស្រ័យ នូវមោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពួកសហេតុកក្ខន្ធ អាស្រ័យ នូវវត្ថុ ក្នុងខណៈនៃបដិសន្ធិ ។

ន សហេតុកំ ន កុសលំ ធម្មំ បដិច្ច ន សហេតុកោ ន កុសលោ ច ន អហេតុកោ ន កុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។ ន អហេតុកំ ន កុសលំ ធម្មំ បដិច្ច ន អហេតុកោ ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ នសហេ-តុកំ ន កុសលញ្ច ន អហេតុកំ ន កុសលញ្ច ធម្មំ បដិច្ច ន សហេតុកោ ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

[២៤៦] ហេតុយា នវ ។

[២៤៧] ន សហេតុកំ ន អកុសលំ ធម្មំ បដិច្ច ន សហេតុកោ ន អកុសលោ ធម្មោ ឧប្បជ្ជតិ ហេ-តុប្បច្ចយា តីណិ ។ ន អហេតុកំ ន អកុសលំ ធម្មំ បដិច្ច ន អហេតុកោ ន អកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ ន សហេតុកំ ន អកុសលញ្ច ន អហេតុកំ ន អកុសលញ្ច ធម្មំ បដិច្ច ន សហេតុ-កោ ន អកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

[២៤៨] ហេតុយា នវ ។

ធម៌ មិនមែនជាសហេតុកៈ មិនមែនជាកុសលក្តី មិនមែនជាអហេតុកៈ មិនមែនជាកុសលក្តី អាស្រ័យ នូវធម៌ មិនមែនជាសហេតុកៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាអហេតុកៈ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាអហេតុកៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាសហេតុកៈ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាសហេតុកៈ មិនមែនជាកុសលផង មិនមែនជាអហេតុកៈ មិនមែនជាកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[២៤៦] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ។

[២៤៧] ធម៌ មិនមែនជាសហេតុកៈ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាសហេតុកៈ មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាអហេតុកៈ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាអហេតុកៈ មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាសហេតុកៈ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាសហេតុកៈ មិនមែនជាអកុសលផង មិនមែនជាអហេតុកៈ មិនមែនជាអកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[២៤៨] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ។

៩៩



[២៤៩] ន សហេតុកំ ន អព្យាកតំ ធម្មំ បដិច្ច ន អហេតុកោ ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឯកំ ។ ន អហេតុកំ ន អព្យាកតំ ធម្មំ បដិច្ច ន អហេតុកោ ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឯកំ ។ ន សហេតុកំ ន អព្យាកតញ្ច ន អហេតុកំ ន អព្យាកតញ្ច ធម្មំ បដិច្ច ន អហេតុកោ ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឯកំ ។

[២៥០] ហេតុយា តីណិ ។

នហេតុសម្បយុត្តទុកំ

នហេតុនសហេតុកទុកសទិសំ ។

## នហេតុសហេតុកទុកនកុសលត្តិកំ

[២៥១] ន ហេតុញ្ចេវ ន អហេតុកញ្ច ន កុសលំ ធម្មំ បដិច្ច ន ហេតុ ចេវ ន អហេតុកោ ច ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន ហេតុញ្ចេវ ន អហេតុកញ្ច ន កុសលំ ធម្មំ បដិច្ច ន អហេតុកោ ចេវ ន នចហេតុ ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

[២៤៩] ធម៌ មិនមែនជាអហេតុកៈ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាសហេតុកៈ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។ ធម៌ មិនមែនជាអហេតុកៈ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាអហេតុកៈ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។ ធម៌ មិនមែនជាអហេតុកៈ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាសហេតុកៈ មិនមែនជាអព្យាកតៈផង មិនមែនជាអហេតុកៈ មិនមែនជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។

[២៥០] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ។

នហេតុសម្បយុត្តទុកៈ ប្រហែលគ្នានឹងនហេតុនសហេតុកទុកៈដែរ ។

# នហេតុសហេតុកទុកនកុសលត្តិកៈ

[២៥១] ធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ (មិនមានហេតុ) មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអហេតុកៈទាំងមិនមែនជាមិនមែនហេតុ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ន ហេតុញ្ចេវ ន អហេតុកញ្ច ន កុសលំ ធម្មំ បដិច្ច ន ហេតុ ចេវ ន អហេតុកោ ច ន កុសលោ ច ន អ-ហេតុកោ ចេវ ន នចហេតុ ន កុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។ ន អហេតុកញ្ចេវ ន នចហេតុំ ន កុសលំ ធម្មំ បដិច្ច ន អហេតុកោ-ចេវ ន នចហេតុ ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេ-តុប្បច្ចយា តីណិ ។ ន ហេតុញ្ចេវ ន អហេតុកញ្ច ន កុសលញ្ច ន អហេតុកញ្ចេវ ន នចហេតុំ ន កុស-លញ្ច ធម្មំ បដិច្ច ន ហេតុ ចេវ ន អហេតុកោ ច ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

[២៨២] ហេតុយា នវ ។

[២៨៣] ន ហេតុញ្ចេវ ន អហេតុកញ្ច ន អកុ-សលំ ធម្មំ បដិច្ច ន ហេតុ ចេវ ន អហេតុកោ ច ន អ-កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[២៨៤] ហេតុយា នវ ។

ធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាកុសលក្តី មិនមែនជាអហេតុកៈ ទាំងមិនមែនជាមិនមែនហេតុ មិនមែនជាកុសលក្តី អាស្រ័យ នូវធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាអហេតុកៈទាំងមិនមែនជាមិនមែនហេតុ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាអហេតុកៈទាំងមិនមែនជាមិនមែនហេតុ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាកុសលផង មិនមែនជាអហេតុកៈទាំងមិនមែនជាមិនមែនហេតុ មិនមែនជាកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[២៥២] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ។

[២៥៣] ធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

[២៥៤] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ។

[២៤៤] ន ហេតុញ្ចេវ ន អហេតុកញ្ច ន អព្យាកតំ ធម្មំ បដិច្ច ន ហេតុ ចេវ ន អហេតុកោ ច ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[២៤៦] ហេតុយា នវ ។

នហេតុចេវនហេតុវិប្បយុត្តទុកំ

នហេតុចេវនហេតុសម្បយុត្តទុកសទិសំ ។

## នហេតុនសហេតុកទុកនកុសលត្តិកំ

[២៤៧] ន ហេតុំ ន សហេតុកំ ន កុសលំ ធម្មំ បដិច្ច ន ហេតុ ន សហេតុកោ ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា នវ ។ ន ហេតុំ ន សហេតុកំ ន អកុសលំ ធម្មំ បដិច្ច ន ហេតុ ន សហេតុកោ ន អកុសលោ . . . នវ[១] ។ ន ហេតុំ ន អហេតុកំ ន អព្យាកតំ ធម្មំ បដិច្ច ន ហេតុ ន អហេតុកោ ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ឯកមេវ[២] ។ ឯតេន ឧបាយេន កុសលាកុសលទុកំ កុសលត្តិកមេវ ឯត្ថ វជ្ជតិ ។

១ ម. នវ បញ្ហា ។ ២ ម. ឯកបញ្ហាមេវ ។

បច្ចនីយទុកត្តិកប្បដ្ឋាន

[២៥៥] ធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាហេតុទាំងមិនមែនជាអហេតុកៈ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[២៥៦] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ។

នហេតុចេវនហេតុវិប្បយុត្តទុកៈ

ប្រហែលគ្នានឹងនហេតុចេវនហេតុសម្បយុត្តទុកៈដែរ ។

# នហេតុនសហេតុកទុកនកុសលត្តិកៈ

[២៥៧] ធម៌ មិនមែនជាហេតុនិងមិនមែនជាសហេតុកៈ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាហេតុនិងមិនមែនជាសហេតុកៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៩ ។ ធម៌ មិនមែនជាហេតុនិងមិនមែនជាសហេតុកៈ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាហេតុនិងមិនមែនជាសហេតុកៈ មិនមែនជាអកុសល . . . មានវារៈ ៩ ។ ធម៌ មិនមែនជាហេតុនិងមិនមែនជាអហេតុកៈ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាហេតុនិងមិនមែនជាអហេតុកៈ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។ ដោយឧបាយនេះ កុសលាកុសលទុកៈ គឺ ជាកុសលត្តិកៈហ្នឹងឯង ទើបគួរ ក្នុងសេចក្តីនេះ ។

# ចូឡន្តរទុកនកុសលត្តិកំ

[២៤៨] ន អប្បច្ចយំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន អសង្ខតំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន សនិទស្សនំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន សប្បដិឃំ ន កុសលំ ធម្មំ បដិច្ច . . . ន អប្បដិឃំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន រូបឹ ន កុសលំ ធម្មំ បដិច្ច . . . ន អរូបឹ ន កុសលំ ធម្មំ បដិច្ច . . . ។ ន លោកិយំ ន កុសលំ ធម្មំ បដិច្ច . . . ន លោកុត្តរំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន កេ-នចិវិញ្ញេយ្យំ ន កុសលំ ធម្មំ បដិច្ច . . . ន កេន-ចិនវិញ្ញេយ្យំ ន កុសលំ ធម្មំ បដិច្ច . . . ។

# នោអាសវគោច្ឆកទុកនកុសលត្តិកំ

[២៤៩] នោ អាសវំ ន កុសលំ ធម្មំ បដិច្ច . . . ន នោអាសវំ ន កុសលំ ធម្មំ បដិច្ច . . . ។

# ចូឡន្តរទុកនកុសលត្តិកៈ

[២៥៨] *អាស្រ័យ នូវធម៌ មិនមែនជាអប្បច្ចយៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាអសង្ខតៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាប្រកបដោយការឃើញ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយការប៉ះពាល់ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមានការប៉ះពាល់ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនមានរូប មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមានរូប មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាលោកិយ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាលោកុត្តរៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ ដែលមិនមែនត្រូវដឹងដោយវិញ្ញាណណានីមួយ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ ដែលមិនមែនជាមិនមែនត្រូវដឹងដោយវិញ្ញាណណានីមួយ មិនមែនជាកុសល . . . ។*

# នោអាសវគោច្ឆកទុកនកុសលត្តិកៈ

[២៥៩] *អាស្រ័យ នូវធម៌ មិនមែនអាសវៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមែនអាសវៈ មិនមែនជាកុសល . . . ។*

ន សាសវំ ន កុសលំ ធម្មំ បដិច្ច . . . ន អនាសវំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន អាសវសម្បយុត្តំ ន កុសលំ ធម្មំ បដិច្ច . . . ន អាសវវិប្បយុត្តំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន អាសវញ្ចេវ ន អនាសវញ្ច ន កុសលំ ធម្មំ បដិច្ច . . . ន អនាសវញ្ចេវ ន នោចអាសវំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន អាសវញ្ចេវ ន អាសវវិប្បយុត្តញ្ច ន កុសលំ ធម្មំ បដិច្ច . . . នអាសវវិប្បយុត្តញ្ចេវ ន នោចអាសវំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន អាសវវិប្បយុត្តំ ន សាសវំ ន កុសលំ ធម្មំ បដិច្ច . . . ន អាសវវិប្បយុត្តំ ន អនាសវំ ន កុសលំ ធម្មំ បដិច្ច . . . ។

# ឆគោច្ឆកទុកនកុសលត្តិកំ

[២៦០] នោសញ្ញោជនំ ន កុសលំ ធម្មំ បដិច្ច . . . ន នោសញ្ញោជនំ ន កុសលំ ធម្មំ បដិច្ច . . . ។ នោគន្ថំ ន កុសលំ ធម្មំ បដិច្ច . . .

*អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងអាសវៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមានអាសវៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយអាសវៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនប្រាសចាកអាសវៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌មិនមែនជាអាសវៈទាំងមិនមែនជាមិនមានអាសវៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមានអាសវៈទាំងមិនមែនជាមិនមែនអាសវៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាអាសវៈទាំងមិនមែនប្រាសចាកអាសវៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនប្រាសចាកអាសវៈទាំងមិនមែនជាមិនមានអាសវៈ មិនមែនជាកុ-សល . . . ។ អាស្រ័យ នូវធម៌ មិនមែនប្រាសចាកអាសវៈនិងមិនមែនប្រព្រឹត្តទៅជាមួយនឹងអាសវៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនប្រាសចាកអាសវៈនិងមិនមែនជាមិនមែនអាសវៈ មិនមែនជាកុសល . . . ។*

# ឆគោច្ឆកទុកនកុសលត្តិកៈ

[២៦០] *អាស្រ័យ នូវធម៌ មិនមែនជាសញ្ញោជនៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមែនសញ្ញោជនៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាគន្ថៈ* (ធម៌ ដោតក្រងសត្វទុកក្នុងវដ្តៈ ដោយអំណាចចុតិនិងបដិសន្ធិ) *មិនមែនជាកុសល . . .*

នោ ឱឃំ . . . នោ យោគំ . . . នោ នីវរណំ . . . នោ បរាមាសំ . . . ។

# មហាន្តរទុកនកុសលត្តិកំ

[២៦១] ន សារម្មណំ . . . ន អនារម្មណំ . . . ។ ន ចិត្តំ ន កុសលំ ធម្មំ បដិច្ច . . . ន នោចិត្តំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន ចេតសិកំ ន កុសលំ ធម្មំ បដិច្ច . . . ។ សង្ខិត្តំ ។ ន ចិត្តសម្បយុត្តំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន ចិត្តសំសដ្ឋំ ន កុសលំ ធម្មំ បដិច្ច . . . ។ នោ ចិត្តសមុដ្ឋានំ ន កុសលំ ធម្មំ បដិច្ច . . . ។ នោ ចិត្តសហភុំ ន កុសលំ ធម្មំ បដិច្ច . . . ។ នោ ចិត្តានុបរិវត្តឹ ន កុសលំ ធម្មំ បដិច្ច . . . ។ នោ ចិត្តសំសដ្ឋសមុដ្ឋានំ ន កុសលំ ធម្មំ បដិច្ច . . . ។ នោ ចិត្តសំសដ្ឋសមុដ្ឋានសហភុំ ន កុសលំ ធម្មំ បដិច្ច . . . ។ នោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តឹ ន កុសលំ ធម្មំ បដិច្ច . . . ។ ន អជ្ឈត្តិកំ ន កុសលំ ធម្មំ បដិច្ច . . . ន ពាហិរំ ន កុសលំ ធម្មំ បដិច្ច . . . ។

មិនមែនជាឱឃៈ . . . មិនមែនជាយោគៈ . . . មិនមែនជានីវរណៈ . . . មិនមែនជាបរាមាសៈ . . . ។

# មហន្តរទុកនកុសលត្តិកៈ

[២៦១] មិនមែនប្រព្រឹត្តទៅ ជាមួយនឹងអារម្មណ៍ . . . មិនមែនជាមិនមែនអារម្មណ៍ . . . ។ អាស្រ័យ នូវធម៌ មិនមែនជាចិត្ត មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមែនចិត្ត មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាចេតសិក មិនមែនជាកុសល . . . ។ សេចក្ដីបំប្រួញ ។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយចិត្ត មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនលាយឡំដោយចិត្ត មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាចិត្តសមុដ្ឋាន មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនកើតជាមួយនឹងចិត្ត មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅតាមចិត្ត មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនលាយឡំនិងតាំងឡើងអំពីចិត្ត មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនលាយឡំតាំងឡើងនិងកើតជាមួយនឹងចិត្ត មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនលាយឡំតាំងឡើងនិងប្រព្រឹត្តទៅតាមចិត្ត មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាខាងក្នុង មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាខាងក្រៅ មិនមែនជាកុសល . . . ។

ន ឧចាធា ន កុសលំ ធម្មំ បដិច្ច . . . ។ ន ឧ-
ចាធិន្នំ ន កុសលំ ធម្មំ បដិច្ច . . . ។

## នោឧបាទានគោច្ឆកទុកនកុសលត្តិកំ

[២៦២] នោ ឧចាធានំ ន កុសលំ ធម្មំ
បដិច្ច . . . ។

## នោកិលេសគោច្ឆកទុកនកុសលត្តិកំ

[២៦៣] នោ កិលេសំ ន កុសលំ ធម្មំ
បដិច្ច . . . ន នោកិលេសំ ន កុសលំ ធម្មំ បដិច្ច
. . . ។ ន សង្កិលេសិកំ ន កុសលំ ធម្មំ បដិច្ច
. . . ន អសង្កិលេសិកំ ន កុសលំ ធម្មំ បដិច្ច
. . . ។ ន សង្កិលិដ្ឋំ ន កុសលំ ធម្មំ បដិច្ច . . .
ន អសង្កិលិដ្ឋំ ន កុសលំ ធម្មំ បដិច្ច . . . ។
ន កិលេសសម្បយុត្តំ ន កុសលំ ធម្មំ បដិច្ច
. . . ន កិលេសវិប្បយុត្តំ ន កុសលំ ធម្មំ បដិច្ច
. . . ។ ន កិលេសញ្ចេវ ន អសង្កិលេសិកញ្ច ន កុ-
សលំ ធម្មំ បដិច្ច . . . ន អសង្កិលេសិកញ្ចេវ ន
នោចកិលេសំ ន កុសលំ ធម្មំ បដិច្ច . . . ។

*អាស្រ័យ នូវធម៌ មិនមែនជាឧបាទា មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ ដែលកម្មប្រកបដោយកិលេស* (មានតណ្ហាជាដើម) *កាន់យក មិនមែនជាកុសល . . . ។*

# នោឧបាទានគោច្ឆកទុកនកុសលត្តិកៈ

[២៦២] *អាស្រ័យ នូវធម៌ មិនមែនជាឧបាទាន មិនមែនជាកុសល . . . ។*

# នោកិលេសគោច្ឆកទុកនកុសលត្តិកៈ

[២៦៣] *អាស្រ័យ នូវធម៌ មិនមែនជាកិលេស មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមែនកិលេស មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនគួរដល់សេចក្តីសៅហ្មង មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនគួរដល់សេចក្តីសៅហ្មង មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនសៅហ្មង មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនសៅហ្មង មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយកិលេស មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនប្រាសចាកកិលេស មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកិលេសទាំងមិនមែនជាមិនគួរដល់សេចក្តីសៅហ្មង មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនគួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាមិនមែនកិលេស មិនមែនជាកុសល . . . ។*

ន កិលេសញ្ចេវ ន អសង្កិលិដ្ឋញ្ច ន កុសលំ ធម្មំ បដិច្ច . . . ន អសង្កិលិដ្ឋញ្ចេវ ន នោចកិលេសំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន កិលេសញ្ចេវ ន កិលេសវិប្បយុត្តញ្ច ន កុសលំ ធម្មំ បដិច្ច . . . ន កិលេសវិប្បយុត្តញ្ចេវ ន នោចកិសេសំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន កិលេសវិប្បយុត្តំ ន សង្កិលេសិកំ ន កុសលំ ធម្មំ បដិច្ច . . . ន កិលេសវិប្បយុត្តំ ន អសង្កិលេសិកំ ន កុសលំ ធម្មំ បដិច្ច . . . ។

# បិដ្ឋិទុកនកុសលត្តិកំ

[២៦៤] ន ទស្សនេន បហាតព្វំ ន កុលសំ ធម្មំ បដិច្ច . . . ន ន ទស្សនេន បហាតព្វំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន ភាវនាយ បហាតព្វំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន ន ភាវនាយ បហាតព្វំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន ទស្សនេន បហាតព្វហេតុកំ ន កុសលំ ធម្មំ បដិច្ច . . . ន នទស្សនេន បហាតព្វហេតុកំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន ភាវនាយ បហាតព្វហេតុកំ ន កុសលំ ធម្មំ បដិច្ច . . .

អាស្រ័យ នូវធម៌ មិនមែនជាកិលេសទាំងមិនមែនជាមិនសៅហ្មង មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនសៅហ្មង ទាំងមិនមែនជាមិនមែនកិលេស មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកិលេសទាំងមិនមែនប្រាសចាកកិលេស មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនប្រាសចាកកិលេសទាំងមិនមែនជាមិនមែនកិលេស មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនប្រាសចាកកិលេសនិងមិនមែនគួរដល់សេចក្តីសៅហ្មង មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនប្រាសចាកកិលេសនិងមិនមែនជាមិនគួរដល់សេចក្តីសៅហ្មង មិនមែនជាកុសល . . . ។

# បិដ្ឋិទុកនកុសលត្តិកៈ

[២៦៤] អាស្រ័យ នូវធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ ដែលមិនមែនជាមិនមែនត្រូវលះដោយទស្សនៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ ដែលមិនមែនត្រូវលះដោយភាវនា មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ ដែលមិនមែនជាមិនមែនត្រូវលះដោយភាវនា មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មានហេតុដែលមិនមែនជាមិនមែនត្រូវលះដោយទស្សនៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មានហេតុដែលមិនមែនត្រូវលះដោយភាវនា មិនមែនជាកុសល . . .

១០៧

បច្ចនីយទុកត្តិកប្បដ្ឋានំ

ន ន ភាវនាយ បហាតព្វហេតុកំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន សវិតក្កំ ន កុសលំ ធម្មំ បដិច្ច . . . ន អវិតក្កំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន សវិចារំ ន កុសលំ ធម្មំ បដិច្ច . . . ន អវិចារំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន សប្បីតិកំ ន កុសលំ ធម្មំ បដិច្ច . . . ន អប្បីតិកំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន បីតិសហគតំ ន កុសលំ ធម្មំ បដិច្ច . . . ន នបីតិ-សហគតំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន សុខ-សហគតំ ន កុសលំ ធម្មំ បដិច្ច . . . ន នសុខស-ហគតំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន ឧបេក្ខា-សហគតំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន នឧបេក្ខា-សហគតំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន កាមាវចរំ ន កុសលំ ធម្មំ បដិច្ច . . . ន នកាមាវចរំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន រូបាវចរំ ន កុសលំ ធម្មំ បដិច្ច . . . ន នរូបាវចរំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន អរូបាវចរំ ន កុសលំ ធម្មំ បដិច្ច . . .

អាស្រ័យ នូវធម៌ មានហេតុដែលមិនមែនជាមិនមែនត្រូវលះដោយភាវ-នា មិនមែនជាកុសល ...។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយវិតក្កៈ មិនមែនជាកុសល ... អាស្រ័យ នូវធម៌ មិនមែនជាអវិតក្កៈ មិនមែនជាកុសល ...។ អាស្រ័យ នូវធម៌ មិនមែនប្រព្រឹត្តទៅជាមួយនឹងវិចារៈ មិនមែនជាកុសល ... អាស្រ័យ នូវធម៌ មិនមែនជាអវិចារៈ មិនមែនជាកុសល ...។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយបីតិ មិនមែនជាកុសល ... អាស្រ័យ នូវធម៌ មិនមែនជាមិនមានបីតិ មិនមែនជាកុសល ...។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយបីតិ មិនមែនជាកុសល ... អាស្រ័យ នូវធម៌ មិនមែនជាមិនមែនប្រកបដោយបីតិ មិនមែនជាកុសល ...។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយសុខ មិនមែនជាកុសល ... អាស្រ័យ នូវធម៌ មិនមែនជាមិនមែនប្រកបដោយសុខ មិនមែនជាកុសល ...។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយឧបេក្ខា មិនមែនជាកុសល ... អាស្រ័យ នូវធម៌ មិនមែនជាមិនមែនប្រកបដោយឧបេក្ខា មិនមែនជាកុសល ...។ អាស្រ័យ នូវធម៌ មិនមែនជាកាមាវចរៈ មិនមែនជាកុសល ... អាស្រ័យ នូវធម៌ មិនមែនជាមិនមែនរូបាវចរៈ មិនមែនជាកុសល ...។ អា-ស្រ័យ នូវធម៌ មិនមែនជារូបាវចរៈ មិនមែនជាកុសល ... អាស្រ័យ នូវធម៌ មិនមែនជាមិនមែនរូបាវចរៈ មិនមែនជាកុសល ...។ អាស្រ័យ នូវធម៌ មិនមែនជាអរូបាវចរៈ មិនមែនជាកុសល ...

ន នអរូបាវចរំ ន កុសលំ ធម្មំ បដិច្ច . . . ។ ន បរិ-
យាបន្នំ ន កុសលំ ធម្មំ បដិច្ច . . . ន អបរិយាបន្នំ
ន កុសលំ ធម្មំ បដិច្ច . . . ។ ន និយ្យានិកំ ន
កុសលំ ធម្មំ បដិច្ច . . . ន អនិយ្យានិកំ ន កុសលំ
ធម្មំ បដិច្ច . . .។ ន និយតំ ន កុសលំ ធម្មំ បដិច្ច
. . . ន អនិយតំ ន កុសលំ ធម្មំ បដិច្ច . . . ។
ន សឧត្តរំ ន កុសលំ ធម្មំ បដិច្ច . . . ន អនុត្តរំ
ន កុសលំ ធម្មំ បដិច្ច . . . ។

[២៦៨] ន សរណំ ន កុសលំ ធម្មំ បដិច្ច
ន សរណោ ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេ-
តុប្បច្ចយា ។ ន អរណំ ន កុសលំ ធម្មំ
បដិច្ច ន អរណោ ន កុសលោ ធម្មោ ឧប្បជ្ជតិ
ហេតុប្បច្ចយា ន អរណំ ន កុសលំ ធម្មំ បដិច្ច
ន សរណោ ន កុសលោ ធម្មោ ឧប្បជ្ជតិ

អាស្រ័យ នូវធម៌ មិនមែនជាមិនមែនអរូបាវចរៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជាបរិយាបន្នៈ (ធម៌ ដែលរាប់បញ្ចូលក្នុងតេភូមិកវដ្តៈ) មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាអបរិយាបន្នៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនជានិយ្យានិកៈ មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាអនិយ្យានិកៈ មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនទៀង មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាមិនទៀង មិនមែនជាកុសល . . . ។ អាស្រ័យ នូវធម៌ មិនមែនប្រកបដោយឧត្តរៈ (ការរើឡើងនូវខ្លួន) មិនមែនជាកុសល . . . អាស្រ័យ នូវធម៌ មិនមែនជាអនុត្តរៈ មិនមែនជាកុសល . . . ។

[២៦៥] ធម៌ មិនមែនជាសរណៈ (ប្រកបដោយកិលេសជាសត្រូវ) មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាអរណៈ (មិនមានកិលេសជាសត្រូវ) មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាសរណៈ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនជាកុសល ទើបកើតឡើង

ហេតុប្បច្ចយា ន អរណំ ន កុសលំ ធម្មំ បដិច្ច ន សរណោ ន កុសលោ ច ន អរណោ ន កុសលោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន សរណំ ន កុសលញ្ច ន អរណំ ន កុសលញ្ច ធម្មំ បដិច្ច ន សរណោ ន កុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[២៦៦] ហេតុយា បញ្ច អវិគតេ បញ្ច ។

[២៦៧] ន សរណំ ន អកុសលំ ធម្មំ បដិច្ច ន សរណោ ន អកុសលោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[២៦៨] ហេតុយា ឯកំ សព្វត្ថ ឯកំ ។

[២៦៩] ន សរណំ ន អព្យាកតំ ធម្មំ បដិច្ច ន សរណោ ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អរណំ ន អព្យាកតំ ធម្មំ បដិច្ច ន អរណោ ន អព្យាកតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាសរណៈ មិនមែនជាកុសលក្តី មិនមែនជាអរណៈ មិនមែនជាកុសលក្តី អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាសរណៈ មិនមែនជាកុសល អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនជាកុសលផង មិនមែនជាអរណៈ មិនមែនជាកុសលផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[២៦៦] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[២៦៧] ធម៌ មិនមែនជាសរណៈ មិនមែនជាអកុសល អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[២៦៨] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

[២៦៩] ធម៌ មិនមែនជាសរណៈ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអរណៈ មិនមែនជាអព្យាកតៈ អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[២៧០] ហេតុយា ទ្វេ អារម្មណេ ទ្វេ អវិគតេ ទ្វេ ។ សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ វិត្ថារោ ។

## នសរណទុកនវេទនាត្តិកំ

[២៧១] ន សរណំ ន សុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច . . . ន សរណំ ន ទុក្ខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច . . . ន សរណំ ន អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ធម្មំ បដិច្ច . . . ។

## នសរណទុកនវិបាកត្តិកំ

[២៧២] ន សរណំ ន វិបាកំ ធម្មំ បដិច្ច . . . ន សរណំ ន វិបាកធម្មធម្មំ បដិច្ច . . . ន សរណំ ន នេវវិបាកនវិបាកធម្មធម្មំ បដិច្ច . . . ។

## នសរណទុកនឧបាទិន្នុបាទានិយត្តិកំ

[២៧៣] ន សរណំ ន ឧបាទិន្នុបាទានិយំ ធម្មំ បដិច្ច . . . ន សរណំ ន អនុបាទិន្នុបាទានិយំ ធម្មំ បដិច្ច . . .

[២៧០] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់ ៗ បច្ច័យ ទាំងអស់ ។

# នសរណទុកនវេទនាត្តិកៈ

[២៧១] អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយសុខវេទនា . . . អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយទុក្ខវេទនា . . . អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយអទុក្ខមសុខវេទនា . . . ។

# នសរណទុកនវិបាកត្តិកៈ

[១៧២] អាស្រ័យ នូវធម៌ មិនមែនជាវិបាក មិនមែនជាសរណៈ . . . អាស្រ័យ នូវធម៌ មិនមែនមានវិបាកជាប្រក្រតី មិនមែនជាសរណៈ . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមែនវិបាកនិងមិនមែនមានវិបាកជាប្រក្រតី មិនមែនជាសរណៈ . . . ។

# នសរណទុកនឧបាទិន្នុបាទានិយត្តិកៈ

[២៧៣] អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនដែលកម្មប្រកបដោយកិលេស (មានតណ្ហាជាដើម) កាន់យកទាំងជាប្រយោជន៍ដល់ឧបាទាន . . . អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនដែលកម្មប្រកបដោយកិលេសមិនកាន់យកទាំងជាប្រយោជន៍ដល់ឧបាទាន . . .

ន សរណំ ន អនុចាជិន្នអនុចាទានិយំ ធម្មំ បដិច្ច . . . ។

។ បេ ។

## នសរណទុកនសនិទស្សនត្តិកំ

[២៧៤] ន សរណំ ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន សរណោ ន សនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សរណំ ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន អរណោ ន សនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន សរណំ ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន សរណោ ន សនិទស្សនសប្បដិឃោ ច ន អរណោ ន សនិទស្សនសប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន អរណំ ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន អរណោ ន សនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនដែលកម្មប្រកបដោយកិលេសមិនកាន់យកទាំងមិនជាប្រយោជន៍ដល់ឧបាទាន . . . ។

។ បេ ។

# នសរណទុកនសនិទស្សនត្តិកៈ

[២៧៨] ធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ក្តី មិនមែនជាអរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ក្តី អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាអរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ន អរណំ ន សនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន ស-
រណោ ន សនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ
ហេតុប្បច្ចយា ន អរណំ ន សនិទស្សនសប្បដិឃំ
ធម្មំ បដិច្ច ន សរណោ ន សនិទស្សនសប្បដិឃោ
ច ន អរណោ ន សនិទស្សនសប្បដិឃោ ច ធម្មា
ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន សរណំ ន សនិទស្ស-
នសប្បដិឃញ្ច ន អរណំ ន សនិទស្សនសប្បដិឃញ្ច
ធម្មំ បដិច្ច ន សរណោ ន សនិទស្សនសប្បដិឃោ
ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

[២៧៥] ហេតុយា នវ ។

[២៧៦] ន សរណំ ន អនិទស្សនសប្បដិឃំ
ធម្មំ បដិច្ច ន សរណោ ន អនិទស្សនសប្បដិ-
ឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ ន អរ-
ណំ ន អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន អរ-
ណោ ន អនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ

ធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ក្តី មិនមែនជាអរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ក្តី អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ផង មិនមែនជាអរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[២៧៥] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ។

[២៧៦] ធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាអរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង

បច្ចនីយទុកត្តិកប្បដ្ឋានំ

ហេតុប្បច្ចយា ន អរណំ ន អនិទស្សនសប្បដិឃំ ធម្មំ បដិច្ច ន សរណោ ន អនិទស្សនសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អរណំ ន អនិទស្សន-សប្បដិឃំ ធម្មំ បដិច្ច ន សរណោ ន អនិទស្សន-សប្បដិឃោ ច ន អរណោ ន អនិទស្សនសប្បដិឃោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ ន សរណំ ន សនិទស្សនសប្បដិឃញ្ច ន អរណំ ន អនិទស្សន-សប្បដិឃញ្ច ធម្មំ បដិច្ច ន សរណោ ន អនិទស្ស-នសប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[២៧៧] ហេតុយា បញ្ច អារម្មណេ ទ្វេ អវិ-គតេ បញ្ច ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ វិត្ថារេតព្វំ ។

ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាសរណៈមិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ក្តី មិនមែនជាអរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ក្តី អាស្រ័យ នូវធម៌ មិនមែនជាអរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ផង មិនមែនជាអរណៈ មិនមែនជាមិនមានការឃើញតែប្រកបដោយការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[២៧៧] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី

បណ្ឌិត គប្បីឲ្យពិស្តារ គ្រប់ ៗ បច្ច័យផងចុះ ។

[២៧៨] ន សរណំ ន អនិទស្សនអប្បដិឃំ ធម្មំ បដិច្ច ន សរណោ ន អនិទស្សនអប្បដិឃោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[២៧៩] ហេតុយា ឯកំ សព្វត្ថ វិត្ថារោ ។

បច្ចនីយទុកត្តិកប្បដ្ឋានំ និដ្ឋិតំ ។

[២៧៨] ធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានការឃើញនិងមិនមានការប៉ះពាល់ អាស្រ័យ នូវធម៌ មិនមែនជាសរណៈ មិនមែនជាមិនមានការឃើញនិងមិនមានការប៉ះពាល់ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។

[២៧៩] ក្នុងហេតុប្បច្ច័យ មានវារៈ ១ សេចក្តីពិស្តារ មានគ្រប់ ៗ បច្ច័យ ទាំងអស់ ។

ចប់ បច្ចនីយទុកត្តិកប្បដ្ឋាន ។

# បច្ចនីយត្តិកទុកប្បដ្ឋានំ

# នកុសលត្តិកនហេតុទុកំ

[២៨០] ន កុសលំ ន ហេតុំ ធម្មំ បដិច្ច ន កុសលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន ហេតុំ ធម្មំ បដិច្ច ន អកុសលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន ហេតុំ ធម្មំ បដិច្ច ន អព្យាកតោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន ហេតុំ ធម្មំ បដិច្ច ន កុសលោ ន ហេតុ ច ន អព្យាកតោ ន ហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន កុសលំ ន ហេតុំ ធម្មំ បដិច្ច ន កុសលោ ន ហេតុ ច ន អកុសលោ ន ហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្ប-ច្ចយា បញ្ច ។

[២៨១] ន អកុសលំ ន ហេតុំ ធម្មំ បដិច្ច ន អកុសលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុ-ប្បច្ចយា ន អកុសលំ ន ហេតុំ ធម្មំ បដិច្ច ន កុ-សលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

# បច្ចនីយត្តិកទុកប្បដ្ឋាន

# នកុសលត្តិកនហេតុទុកៈ

[២៨០] ធម៌ មិនមែនជាកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះ ហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះ ហេតុប្បច្ច័យ ធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះ ហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាហេតុក្តី មិនមែនជា អព្យាកតៈ មិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជា កុសល មិនមែនជាហេតុក្តី មិនមែនជាអកុសល មិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[២៨១] ធម៌ មិនមែនជាអកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះ ហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ន អកុសលំ ន ហេតុំ ធម្មំ បដិច្ច ន អព្យាកតោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អកុសលំ ន ហេតុំ ធម្មំ បដិច្ច ន អកុសលោ ន ហេតុ ច ន អព្យាកតោ ន ហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្ប-ច្ចយា ន អកុលសំ ន ហេតុំ ធម្មំ បដិច្ច ន កុស-លោ ន ហេតុ ច ន អកុសលោ ន ហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។

[២៨២] ន អព្យាកតំ ន ហេតុំ ធម្មំ បដិច្ច ន អព្យាកតោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អព្យាកតំ ន ហេតុំ ធម្មំ បដិច្ច ន កុសលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អព្យាកតំ ន ហេតុំ ធម្មំ បដិច្ច ន អកុសលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អព្យាកតំ ន ហេតុំ ធម្មំ បដិច្ច ន កុសលោ ន ហេតុ ច ន អព្យាកតោ ន ហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន អព្យា-កតំ ន ហេតុំ បដិច្ច ន អកុសលោ ន ហេតុ ច ន អព្យាកតោ ន ហេតុ ច ធម្មា ឧប្បជ្ជន្តិ

ធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល មិនមែនជាហេតុក្តី មិនមែនជាអព្យាកតៈ មិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាហេតុក្តី មិនមែនជាអកុសល មិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៩ ។

[២៨២] ធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាហេតុក្តី មិនមែនជាអព្យាកតៈ មិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល មិនមែនជាហេតុក្តី មិនមែនជាអព្យាកតៈ មិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ ទើបកើតឡើង

ហេតុប្បច្ចយា ន អព្យាកតំ ន ហេតុំ ធម្មំ បដិច្ច ន កុសលោ ន ហេតុ ច ន អកុសលោ ន ហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ឆ ។

[២៨៣] ន កុសលំ ន ហេតុញ្ច ន អព្យាកតំ ន ហេតុញ្ច ធម្មំ បដិច្ច ន កុសលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន ហេតុញ្ច ន អព្យាកតំ ន ហេតុញ្ច ធម្មំ បដិច្ច ន អកុសលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន ហេតុញ្ច ន អព្យាកតំ ន ហេតុញ្ច ធម្មំ បដិច្ច ន អព្យាកតោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ច-យា បញ្ច ។

[២៨៤] ន អកុសលំ ន ហេតុញ្ច ន អព្យាកតំ ន ហេតុញ្ច ធម្មំ បដិច្ច ន កុសលោ ន ហេតុ ធម្មោ ឧប្ប-ជ្ជតិ ហេតុប្បច្ចយា ន អកុសលំ ន ហេតុញ្ច ន អព្យាក-តំ ន ហេតុញ្ច ធម្មំ បដិច្ច ន អកុសលោ ន ហេតុ ធម្មោ

ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាហេតុក្តី មិនមែនជាអកុសល មិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។

[២៨៣] ធម៌ មិនមែនជាកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុផង មិនមែនជាអព្យាកតៈ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុផង មិនមែនជាអព្យាកតៈ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុផង មិនមែនជាអព្យាកតៈ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៩ ។

[២៨៤] ធម៌ មិនមែនជាកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាហេតុផង មិនមែនជាអព្យាកតៈ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាហេតុផង មិនមែនជាអព្យាកតៈ មិនមែនជាហេតុផង

ឧប្បជ្ជតិ ហេតុប្បច្ចយា ន អកុសលំ ន ហេតុញ្ច ន អព្យាកតំ ន ហេតុញ្ច ធម្មំ បដិច្ច ន អព្យាកតោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា បញ្ច ។

[២៨៥] ន កុសលំ ន ហេតុញ្ច ន អកុសលំ ន ហេតុញ្ច ធម្មំ បដិច្ច ន កុសលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន ហេតុញ្ច ន អកុសលំ ន ហេតុញ្ច ធម្មំ បដិច្ច ន អកុសលោ ន ហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន ហេតុញ្ច ន អកុសលំ ន ហេតុញ្ច ធម្មំ បដិច្ច ន កុសលោ ន ហេតុ ច ន អកុសលោ ន ហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។

[២៨៦] ហេតុយា ឯកូនវីស អារម្មណេ ចតុ-វីស អវិគតេ ឯកូនវីស សព្វត្ថ វិត្ថារោ ។

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអព្យាកតៈ មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាហេតុផង មិនមែនជាអព្យាកតៈ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

[២៨៥] ធម៌ មិនមែនជាកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុផង មិនមែនជាអកុសល មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល មិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុផង មិនមែនជាអកុសល មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាហេតុក្តី មិនមែនជាអកុសល មិនមែនជាហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុផង មិនមែនជាអកុសល មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[២៨៦] ក្នុងហេតុប្បច្ច័យ មានវារៈ ២៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៩ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

១១៩

បច្ចនីយត្តិកទុកប្បដ្ឋានំ

[២៨៧] ន កុសលំ ន នហេតុំ ធម្មំ បដិច្ច ន កុសលោ ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន នហេតុំ ធម្មំ បដិច្ច ន អកុសលោ ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន នហេតុំ ធម្មំ បដិច្ច ន អព្យាកតោ ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន នហេតុំ ធម្មំ បដិច្ច ន កុសលោ ន នហេតុ ច ន អព្យាកតោ ន នហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ន កុសលំ ន នហេតុំ ធម្មំ បដិច្ច ន កុសលោ ន នហេតុ ច ន អកុសលោ ន នហេតុ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា បញ្ច ។ ន អ-កុសលំ ន នហេតុំ ធម្មំ បដិច្ច ន អកុសលោ ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា បញ្ច ។ ន អព្យាកតំ ន នហេតុំ ធម្មំ បដិច្ច ន អព្យាកតោ ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា បញ្ច ។

បច្ចនីយត្តិកទុកប្បដ្ឋាន

[២៨៧] ធម៌ មិនមែនជាកុសល មិនមែនជាមិនមែនជាហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល មិនមែនជាមិនមែនហេតុ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាមិនមែនហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអព្យា-កតៈ មិនមែនជាមិនមែនហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុក្តី មិនមែនជាអព្យាកតៈ មិនមែនជាមិនមែនហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុក្តី មិនមែនជាអកុសល មិនមែនជាមិនមែនហេតុក្តី អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។ ធម៌ មិនមែនជាអកុសល មិនមែនជាមិនមែនហេតុ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាមិនមែនហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។ ធម៌ មិនមែនជាអព្យាកតៈ មិនមែនជាមិនមែនហេតុ អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ មិនមែនជាមិនមែនហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

ន កុសលំ ន នហេតុញ្ច ន អព្យាកតំ ន នហេតុញ្ច ធម្មំ បដិច្ច ន កុសលោ ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ ន អកុសលំ ន នហេតុញ្ច ន អព្យាកតំ ន នហេតុញ្ច ធម្មំ បដិច្ច ន អកុសលោ ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ ន កុសលំ ន នហេតុញ្ច ន អកុសលំ ន នហេតុញ្ច ធម្មំ បដិច្ច ន កុសលោ ន នហេតុ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

[២៨៨] ហេតុយា ចតុវីស អារម្មណេ ចតុវីស អវិគតេ ចតុវីស សព្វត្ថ វិត្ថារោ ។

## នកុសលត្តិកនសហេតុកទុកំ

[២៨៩] ន កុសលំ ន សហេតុកំ ធម្មំ បដិច្ច ន កុសលោ ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន កុសលំ ន សហេតុកំ ធម្មំ បដិច្ច ន អកុសលោ ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា

ធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុផង មិនមែនជាអព្យាកតៈ មិនមែនជាមិនមែនហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាអកុសល មិនមែនជាមិនមែនហេតុ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាមិនមែនហេតុផង មិនមែនជាអព្យាកតៈ មិនមែនជាមិនមែនហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនហេតុផង មិនមែនជាអកុសល មិនមែនជាមិនមែនហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[២៨៨] ក្នុងហេតុប្បច្ច័យ មានវារៈ ២៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២៤ ក្នុងអវិគតប្បច្ច័យ មានវារៈ២៤ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

# នកុសលត្តិកនសហេតុកទុកៈ

[២៨៩] ធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈ (ប្រកបដោយហេតុ) អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាអកុសល មិនមែនជាសហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

ន កុសលំ ន សហេតុកំ ធម្មំ បដិច្ច ន កុសលោ ន សហេតុកោ ច ន អកុសលោ ន សហេតុកោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។ ន អកុ-សលំ ន សហេតុកំ ធម្មំ បដិច្ច ន អកុសលោ ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អកុសលំ ន សហេតុកំ ធម្មំ បដិច្ច ន កុសលោ ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ន អកុសលំ ន សហេតុកំ ធម្មំ បដិច្ច ន កុសលោ ន សហេតុកោ ច ន អកុសលោ ន សហេតុកោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា តីណិ ។ ន អព្យា-កតំ ន សហេតុកំ ធម្មំ បដិច្ច ន កុសលោ ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ ន កុសលំ ន សហេតុកញ្ច ន អព្យាកតំ ន សហេ-តុកញ្ច ធម្មំ បដិច្ច ន កុសលោ ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ ន កុសលំ ន សហេតុកញ្ច ន អកុសលំ ន សហេតុកញ្ច ធម្មំ បដិច្ច ន កុសលោ ន សហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

ធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈផង មិនមែនជាអកុសល មិនមែនជាសហេតុកៈផង អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាអកុសល មិនមែនជាសហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាសហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាសហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈផង មិនមែនជាអកុសល មិនមែនជាសហេតុកៈផង អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាសហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ មិនមែនជាសហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈផង មិនមែនជាអព្យាកតៈ មិនមែនជាសហេតុកៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាសហេតុកៈផង មិនមែនជាអកុសល មិនមែនជាសហេតុកៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[២៩០] ហេតុយា បណ្ណរស អារម្មណេ នវ អវិគតេ បណ្ណរស សព្វត្ថ វិត្ថារោ ។

[២៩១] ន កុសលំ ន អហេតុកំ ធម្មំ បដិច្ច ន កុសលោ ន អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា បញ្ច ។ ន អកុសលំ ន អហេតុកំ ធម្មំ បដិច្ច ន អកុសលោ ន អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា បញ្ច ។ ន អព្យាកតំ ន អហេតុកំ ធម្មំ បដិច្ច ន អព្យាកតោ ន អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា បញ្ច ។ ន កុសលំ ន អហេតុកញ្ច ន អព្យាកតំ ន អហេតុកញ្ច ធម្មំ បដិច្ច ន កុសលោ ន អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ ន អកុសលំ ន អហេតុកញ្ច ន អព្យាកតំ ន អហេតុកញ្ច ធម្មំ បដិច្ច ន អកុសលោ ន អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ ន កុសលំ ន អហេតុកញ្ច ន អកុសលំ ន អហេតុកញ្ច ធម្មំ បដិច្ច ន អកុសលោ ន អហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

[២៩០] ក្នុងហេតុប្បច្ច័យ មានវារៈ ១៥ ក្នុងអារម្មណប្ប-ច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៥ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[២៩១] ធម៌ មិនមែនជាកុសល មិនមែនជាអហេតុកៈ (មិនមានហេតុ) អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។ ធម៌ មិនមែនជាអកុសល មិនមែនជាអហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាអហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។ ធម៌ មិនមែនជាអព្យាកតៈ មិនមែនជាអហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាអព្យាកតៈ មិនមែនជាអហេតុកៈ ទើបកើតឡើង ព្រោះហេតុ-ប្បច្ច័យ មានវារៈ ៥ ។ ធម៌ មិនមែនជាកុសល មិនមែនជាអហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអហេតុកៈផង មិនមែនជាអព្យាកតៈ មិនមែនជាអហេតុកៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាអកុសល មិនមែនជាអហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាអកុសល មិនមែនជាអហេតុកៈផង មិនមែនជាអព្យាកតៈ មិនមែនជាអហេតុកៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាអកុសល មិនមែនជាអហេតុកៈ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអហេ-តុកៈផង មិនមែនជាអកុសល មិនមែនជាអហេតុកៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[២៩២] ហេតុយា ចតុព្វីស អវិគតេ ចតុព្វីស សព្វត្ថ វិត្ថារោ ។

## នកុសលត្តិកនហេតុសម្បយុត្តទុកំ

[២៩៣] ន កុសលំ ន ហេតុសម្បយុត្តំ ធម្មំ បដិច្ច . . . ន កុសលំ ន ហេតុវិប្បយុត្តំ ធម្មំ បដិច្ច . . . ។

## នកុសលត្តិកនហេតុសហេតុកទុកំ

[២៩៤] ន កុសលំ ន ហេតុញ្ចេវ ន អហេតុកញ្ច ធម្មំ បដិច្ច . . . ន កុសលំ ន អហេតុកញ្ចេវ ន នហេតុញ្ច ធម្មំ បដិច្ច . . . ។

## នកុសលត្តិកនហេតុហេតុសម្បយុត្តទុកំ

[២៩៥] ន កុសលំ ន ហេតុញ្ចេវ ន ហេតុវិប្បយុត្តញ្ច ធម្មំ បដិច្ច . . . ន កុសលំ ន ហេតុវិប្បយុត្តញ្ចេវ ន នហេតុញ្ច ធម្មំ បដិច្ច . . . ។

## នកុសលត្តិកនហេតុនសហេតុកទុកំ

[២៩៦] ន កុសលំ ន ហេតុំ ន សហេតុកំ ធម្មំ បដិច្ច . . . ន កុសលំ ន ហេតុំ ន អហេតុកំ ធម្មំ បដិច្ច . . . ។

[២៩២] *ក្នុងហេតុប្បច្ច័យ មានវារៈ ២៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៤ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។*

## នកុសលត្តិកនហេតុសម្បយុត្តទុកៈ

[២៩៣] *អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុសម្បយុត្ត* (ប្រកបដោយហេតុ) . . . *អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុវិប្បយុត្ត* (ប្រាសចាកហេតុ) . . . ។

## នកុសលត្តិកនហេតុសហេតុកទុកៈ

[២៩៤] *អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុ ទាំងមិនមែនជាអហេតុកៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអហេតុកៈទាំងមិនមែនជាមិនមែនហេតុ . . . ។*

## នកុសលត្តិកនហេតុហេតុសម្បយុត្តទុកៈ

[២៩៥] *អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុទាំងមិនមែនជាហេតុវិប្បយុត្ត . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុវិប្បយុត្តទាំងមិនមែនជាមិនមែនហេតុ . . . ។*

## នកុសលត្តិកនហេតុនសហេតុកទុកៈ

[២៩៦] *អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុនិងមិនមែនជាសហេតុកៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាហេតុនិងមិនមែនជាអហេតុកៈ . . . ។*

# នកុសលត្តិកចូឡន្តរទុកំ

[២៩៧] ន កុសលំ ន អប្បច្ចយំ ធម្មំ បដិច្ច ...។ ន កុសលំ ន អសង្ខតំ ធម្មំ បដិច្ច ...។ ន កុសលំ ន សនិទស្សនំ ធម្មំ បដិច្ច ... ន កុសលំ ន អនិទស្សនំ ធម្មំ បដិច្ច ...។ ន កុសលំ ន សប្បដិឃំ ធម្មំ បដិច្ច ... ន កុសលំ ន អប្បដិឃំ ធម្មំ បដិច្ច ...។ ន កុសលំ ន រូបឹ ធម្មំ បដិច្ច ... ន កុសលំ ន អរូបឹ ធម្មំ បដិច្ច ...។ ន កុសលំ ន លោកិយំ ធម្មំ បដិច្ច ... ន កុសលំ ន លោកុត្តរំ ធម្មំ បដិច្ច ...។ ន កុសលំ ន កេនចិវិញ្ញេយ្យំ ធម្មំ បដិច្ច ... ន កុសលំ ន កេនចិនវិញ្ញេយ្យំ ធម្មំ បដិច្ច ...។

# នកុសលត្តិកចូឡន្តរទុកៈ

[២៩៧] អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអប្បច្ច័យ . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអសង្ខតៈ . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាសនិទស្សនៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអនិទស្សនៈ . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាសប្បដិឃៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអប្បដិឃៈ . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនមានរូប . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមានរូប . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាលោកិយ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនលោកុត្តរៈ . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនត្រូវដឹងដោយវិញ្ញាណណានីមួយ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនត្រូវដឹងដោយវិញ្ញាណណានីមួយ . . . ។

១២៨

បច្ចនីយត្តិកទុកប្បដ្ឋានំ

# នកុសលត្តិកនោអាសវគោច្ឆកទុកំ

[២៩៨] ន កុសលំ នោ អាសវំ ធម្មំ បដិច្ច ...ន កុសលំ ន នោអាសវំ ធម្មំ បដិច្ច ...។ ន កុសលំ ន សាសវំ ធម្មំ បដិច្ច ...ន កុសលំ ន អនាសវំ ធម្មំ បដិច្ច ...។ ន កុសលំ ន អាសវសម្បយុត្តំ ធម្មំ បដិច្ច ...ន កុសលំ ន អាសវវិប្បយុត្តំ ធម្មំ បដិច្ច ...។ ន កុសលំ ន អាសវញ្ចេវ ន អនាសវញ្ច ធម្មំ បដិច្ច ...ន កុសលំ ន អនាសវញ្ចេវ ន នោចអាសវំ ធម្មំ បដិច្ច ...។ ន កុសលំ ន អាសវញ្ចេវ ន អាសវវិប្បយុត្តញ្ច ធម្មំ បដិច្ច ...ន កុសលំ ន អាសវវិប្បយុត្តញ្ចេវ ន នោចអាសវំ ធម្មំ បដិច្ច ...។ ន កុសលំ អាសវវិប្បយុត្តំ ន សាសវំ ធម្មំ បដិច្ច ...ន កុសលំ អាសវវិប្បយុត្តំ ន អនាសវំ ធម្មំ បដិច្ច ...។

បច្ចនីយត្តិកទុកប្បដ្ឋាន

# នកុសលត្តិកនោអាសវគោច្ឆកទុកៈ

[២៩៨] *អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអាសវៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនអាសវៈ . . .។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនប្រព្រឹត្តទៅជាមួយនឹងអាសវៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមានអាសវៈ . . .។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអាសវសម្បយុត្ត . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអាសវវិប្បយុត្ត . . .។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអាសវៈទាំងមិនមែនជាមិនមានអាសវៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមានអាសវៈទាំងមិនមែនជាមិនមែនអាសវៈ . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអាសវៈទាំងមិនមែនជាអាសវវិប្បយុត្ត . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអាសវវិប្បយុត្តទាំងមិនមែនជាមិនមែនអាសវៈ . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល ជាអាសវវិប្បយុត្តទាំងមិនមែនប្រព្រឹត្តទៅជាមួយនឹងអាសវៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល ជាអាសវវិប្បយុត្តទាំងមិនមែនជាមិនមានអាសវៈ . . . ។*

# នកុសលត្តិកឆគោច្ឆកទុកំ

[២៩៩] ន កុសលំ នោ សញ្ញោជនំ ធម្មំ បដិច្ច . . . ន កុសលំ នោ គន្ថំ ធម្មំ បដិច្ច . . . ន កុសលំ នោ ឱឃំ ធម្មំ បដិច្ច . . . ន កុសលំ នោ យោគំ ធម្មំ បដិច្ច . . . ន កុសលំ នោ នីវរណំ ធម្មំ បដិច្ច . . . ន កុសលំ នោ បរាមាសំ ធម្មំ បដិច្ច . . . ។

# នកុសលត្តិកមហន្តរទុកំ

[៣០០] ន កុសលំ ន សារម្មណំ ធម្មំ បដិច្ច . . . ន កុសលំ ន អនារម្មណំ ធម្មំ បដិច្ច . . . ។ សង្ខិត្តំ ។ ន នោចិត្តបទំ ន លព្ភតិ ។ ន កុសលំ ន ចិត្តំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ចេតសិកំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ចិត្តសម្បយុត្តំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ចិត្តសំសដ្ឋំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ចិត្តសមុដ្ឋានំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ចិត្តសហភុំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ចិត្តានុបរិវត្តឹ ធម្មំ បដិច្ច . . . ។

# នកុសលត្តិកឆគោច្ឆកទុកៈ

[២៩៩] អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាសញ្ញោជនៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាគន្ថៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាឱឃៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាយោគៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជានីវរណៈ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាបរាមាសៈ . . . ។

# នកុសលត្តិកមហន្តរទុកៈ

[៣០០] អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមានអារម្មណ៍ . . . ។ សេចក្តីបំប្រួញ ។ មិនសំដៅយកនូវបទ ដែលមិនមែនជាមិនមែនចិត្តទេ ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាចិត្ត . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាចេតសិក . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាចិត្តសម្បយុត្ត . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនលាយឡំដោយចិត្ត . . . ។ អាស្រ័យនូវធម៌ មិនមែនជាកុសល មិនមែនជាចិត្តសមុដ្ឋាន . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនកើតឡើង ជាមួយនឹងចិត្ត . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនប្រព្រឹត្តទៅតាមចិត្ត . . . ។

ន កុសលំ ន ចិត្តសំសដ្ឋសមុដ្ឋានំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ចិត្តសំសដ្ឋសមុដ្ឋានសហភុំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តឹ ធម្មំ បដិច្ច . . . ។ ន កុសលំ ន អជ្ឈត្តិកំ ធម្មំ បដិច្ច . . . ន កុសលំ ន ពាហិរំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ឧបាទា ធម្មំ បដិច្ច . . . ។ ន កុសលំ ន ឧបាទិន្នំ ធម្មំ បដិច្ច . . . ន កុសលំ ន អនុបាទិន្នំ ធម្មំ បដិច្ច . . . ។

## នកុសលត្តិកទ្វិគោច្ឆកទុកំ

[៣០១] ន កុសលំ នោ ឧបាទានំ ធម្មំ បដិច្ច . . . ន កុសលំ ន នោឧបាទានំ ធម្មំ បដិច្ច . . . ។ ន កុសលំ នោ កិលេសំ ធម្មំ បដិច្ច . . . ន កុសលំ ន នោកិលេសំ ធម្មំ បដិច្ច . . . ។

[៣០២] ន កុសលំ ន ទស្សនេន បហាតព្វំ ធម្មំ បដិច្ច . . . ន នកុសលំ ន នទស្សនេន បហាតព្វំ ធម្មំ បដិច្ច . . . ។

អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនលាយឡំនិងតាំងឡើងអំពីចិត្ត . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនលាយឡំតាំងឡើងនិងកើតជាមួយនឹងចិត្ត . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនលាយឡំតាំងឡើងនិងប្រព្រឹត្តទៅតាមចិត្ត . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាខាងក្នុង . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាខាងក្រៅ . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាឧបាទា . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាឧបាទិន្ន . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាអនុបាទិន្ន . . . ។

# នកុសលត្តិកទ្វិគោច្ឆកទុកៈ

[៣០១] អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាឧបាទាន . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនឧបាទាន . . . ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាកិលេស . . . អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនកិលេស . . . ។

[៣០២] អាស្រ័យ នូវធម៌ មិនមែនជាកុសល ដែលមិនមែនត្រូវលះដោយទស្សនៈ . . . អាស្រ័យ នូវធម៌ មិនមែនជាមិនមែនជាកុសល ដែលមិនមែនជាមិនមែនត្រូវលះដោយទស្សនៈ . . . ។

ន កុសលំ ន ភាវនាយ បហាតព្វំ ធម្មំ បដិច្ច . . . ន កុសលំ ន ន ភាវនាយ បហាតព្វំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ទស្សនេន បហាតព្វហេតុកំ ធម្មំ បដិច្ច . . . ន កុសលំ ន ន ទស្សនេន បហាតព្វហេតុកំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន ភាវនាយ បហា-តព្វហេតុកំ ធម្មំ បដិច្ច . . . ន កុសលំ ន ន ភា-វនាយ បហាតព្វហេតុកំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន សវិតក្កំ ធម្មំ បដិច្ច . . . ន កុសលំ ន អវិតក្កំ បដិច្ច . . . ។ ន កុសលំ ន សវិ-ចារំ ធម្មំ បដិច្ច . . . ន កុសលំ ន អវិចារំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន សប្បីតិកំ ធម្មំ បដិច្ច . . . ន កុសលំ ន អប្បីតិកំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន បីតិសហគតំ ធម្មំ បដិច្ច . . . ន កុ-សលំ ន នបីតិសហគតំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន សុខសហគតំ ធម្មំ បដិច្ច . . . ន កុ-លសំ ន នសុខសហគតំ ធម្មំ បដិច្ច . . . ។

អាស្រ័យ នូវធម៌ មិនមែនជាកុសល ដែលមិនមែនត្រូវលះដោយភាវនា ....អាស្រ័យ នូវធម៌ មិនមែនជាកុសល ដែលមិនមែនជាមិនមែនត្រូវលះដោយភាវនា ...។ អាស្រ័យ នូវធម៌ មិនមែនជាកុសល ដែលមិនមែនមានហេតុត្រូវលះដោយទស្សនៈ ... អាស្រ័យ នូវធម៌ មិនមែនជាកុសល ដែលមិនមែនជាមិនមែនមានហេតុត្រូវលះដោយទស្សនៈ ...។ អាស្រ័យ នូវធម៌ មិនមែនជាកុសល ដែលមិនមែនមានហេតុត្រូវលះដោយភាវនា ... អាស្រ័យ នូវធម៌ មិនមែនជាកុសល ដែលមិនមែនជាមិនមែនមានហេតុត្រូវលះដោយភាវនា ... ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ... អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមានវិតក្កៈ ...។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនប្រព្រឹត្តទៅជាមួយនឹងវិចារៈ ... អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមានវិចារៈ ...។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនប្រព្រឹត្តទៅជាមួយនឹងបីតិ ... អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមានបីតិ ... ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនប្រកបដោយបីតិ ... អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនប្រកបដោយបីតិ ... ។ អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនប្រកបដោយសុខ ... អាស្រ័យ នូវធម៌ មិនមែនជាកុសល មិនមែនជាមិនមែនប្រកបដោយសុខ ...។

បច្ចនីយត្តិកទុកប្បដ្ឋានំ

ន កុសលំ ន ឧបេក្ខាសហគតំ ធម្មំ បដិច្ច . . . ន កុសលំ ន នឧបេក្ខាសហគតំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន កាមាវចរំ ធម្មំ បដិច្ច . . . ន កុសលំ ន នកាមាវចរំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន រូបាវចរំ ធម្មំ បដិច្ច . . . ន កុសលំ ន នរូបាវចរំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន អរូបាវចរំ ធម្មំ បដិច្ច . . . ន កុសលំ ន នអរូបាវចរំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន បរិយាបន្នំ ធម្មំ បដិច្ច . . . ន កុសលំ ន អបរិយាបន្នំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន និយ្យានិកំ ធម្មំ បដិច្ច . . . ន កុសលំ ន អនិយ្យានិកំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន និយតំ ធម្មំ បដិច្ច . . . ន កុសលំ ន អនិយតំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន សឧត្តរំ ធម្មំ បដិច្ច . . . ។ ន កុសលំ ន អនុត្តរំ ធម្មំ បដិច្ច . . . ។

[៣០៣] ន កុសលំ ន សរណំ ធម្មំ បដិច្ច ន កុសលោ ន សរណោ ធម្មោ ឧប្បជ្ជតិ

